ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Dec-2015, 09:52
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# **<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

## **<u>ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ</u>**

## **<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី៣៥០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក កែវ វ៉ាត

លោកស្រី អេវេលីន ខាំផូស សង់ចេស

*(Mrs. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក 2-TCW-1000 | ខ្មែរ |

# ខ្លឹមសារ

## ការសួរសំណួរទៅសាក្សី ៖ លោក 2-TCW-1000

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ១០
សួរដោយ លោក នីកូឡាស គូមជែន ផ្ដើមពី........ ទំព័រ ១២
សួរដោយ លោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........ ទំព័រ ៣៩
សួរដោយ ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្ដើមពី ........ ទំព័រ ៤៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ សវនាការនៅថ្ងៃ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សាក្សីដែលមានរហស្សនាម 2-TCW-1000។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាព វត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះ នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺមានរហស្សនាម 2-TCW-1000។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះ បានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយ កាលពីព្រឹកមិញនេះ។ សាក្សីមានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ដែលបានបញ្ជាក់

ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

[០៩:១១:២៨]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

បានកំណត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថានៅថ្ងៃនេះ គាត់មានអាការៈឈឺចង្កេះ អង្គុយ នៅពេលអង្គុយយូរ និងវិលមុខ នៅពេលធ្វើចលនា និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវ-នាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដែលមានបំណងធ្វើសារណាកាលពីម្សិលមិញ ហើយអង្គជំនុំជម្រះបានលើកពេលមកស្ដាប់សារណានៅថ្ងៃនេះ។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ភាគីទាំងអស់។ បាទ តាមពិត ខ្ញុំចង់ធ្វើសេចក្ដីសន្និដ្ឋានមួយចំនួនទាក់ទងទៅនឹងសាក្សីដែលមកធ្វើសក្ខីកម្មនៅទីនេះ នៅ១៣ថ្ងៃមុន គឺនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ បុគ្គលនោះ ឈ្មោះ ប្រាក់ ឌឿន។ លោកប្រធាន ប្រហែលជាចាំហើយ នៅពេលព្រឹក មានការពិភាក្សាអំពីបញ្ហាមួយចំនួន សំណួរមួយចំនួន។ ខ្ញុំចង់សួរសាក្សីរូបនេះ

គាត់បានផ្តល់បទសម្ភាសន៍សក្ខីកម្មមួយ ទាក់ទងទៅនឹងការសម្លាប់ប្រពន្ធរបស់គាត់ជនជាតិវៀតណាម ហើយបញ្ជាក់ថា ការកាប់សម្លាប់ ការសម្លាប់នោះ គឺធ្វើឡើងដោយកម្មាភិបាលមកពីតំបន់។

[០៩:១៣:៥៥]

ដល់ពេលត្រូវវេនរបស់ខ្ញុំត្រូវសួរសំណួរនោះ ខ្ញុំចង់ដឹងពីគាត់ថា តើគាត់ទទួលការចោទប្រកាន់ថា គាត់បានសម្លាប់ប្រពន្ធខ្លួនឯងដែរឬទេនោះ។ លោកប្រធានប្រហែលជានៅចាំ។ នៅពេលដែលចៅក្រម ហ្វេនស៍ សួរខ្ញុំ ពេលដែលខ្ញុំសួរសំណួរទៅសាក្សី ខ្ញុំបានឆ្លើយថាសំណួរនោះ គឺជំរុញដោយចំណុចមួយដែលគាត់បានបញ្ជាក់ខ្លួនគាត់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ គឺ E3/4989 ដែលខ្ញុំគិតថា ចេញពីចំណុចមិនច្បាស់លាស់ គាត់បាននិយាយថា នៅក្នុងពាក្យសុំតាំងខ្លួនរបស់គាត់ -- ខ្ញុំដកស្រង់ពាក្យគាត់ "ខ្ញុំសូមបដិសេធថា ខ្មែរក្រហមមិនដែលបានបង្ខំខ្ញុំឱ្យសម្លាប់ប្រពន្ធខ្ញុំទេ។ ខ្ញុំស្បថថាការណ៍នេះគឺមិនពិតទេ"។

សំណួរដែលខ្ញុំចង់សួរទៅគាត់ ដូចដែលខ្ញុំបញ្ជាក់នោះ គឺថា ខ្ញុំសួរគាត់ថាតើលោកធ្លាប់បានទទួលការចោទប្រកាន់ថា លោកពាក់ព័ន្ធដោយខ្លួនឯងជាមួយនឹងការសម្លាប់ប្រពន្ធរបស់ខ្លួនទេ ហើយសួរគាត់ ថាតើមានបណ្តឹងព្រហ្មទណ្ឌណាប្រឆាំងនឹងគាត់ទេ នៅទសវត្សរ៍ឆ្នាំ៨0? ហើយនិងសំណួរទាំងអស់ហ្នឹង ទាក់ទងទៅនឹងភាពជឿជាក់បាននៃសាក្សីរូបនេះ។ ដូចដែលខ្ញុំជម្រាប គឺដូចដែលលោកប្រធានចាំហើយ គឺខ្ញុំត្រូវបានហាមឃាត់មិនឱ្យសួរសំណួរទាំងនោះទេ ប៉ុន្តែនៅដំណាក់កាលក្រោយបន្ទាប់ពីនោះមក យើងក៏បានប្រទះទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត គឺថាបន្ទាប់ពីសាក្សីនោះបានបញ្ចប់ទៅ ហើយជាសំណេរផ្ទាល់ដៃនៃពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សេចក្តីថ្លែងការណ៍របស់ជនរងគ្រោះ។ ចម្លើយនោះដែលបានសរសេរជាសេចក្តីព្រាងដែលធ្វើឡើងដោយមេធាវីដដែល។ ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប្រាក់ ឌឿន ដែរ។ ជន -- ចម្លើយរបស់ជនរងគ្រោះនេះ គឺ E3/4732 ហើយអត្ថបទជាភាសាអង់គ្លេសនោះ គឺជាភាសាដើម គឺដែលមានផ្តិតមេដៃរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅទំព័រអង់គ្លេស 00427379 ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បញ្ជាក់ដូចខាងក្រោមនេះ។

[០៩:១៦:៣៥]

ខ្ញុំសូមដកស្រង់៖ "ខ្ញុំដឹងអំពីប្តីខ្មែរម្នាក់ដែលត្រូវបានគេបញ្ជា ត្រូវបានគេបង្ខំឱ្យសម្លាប់ប្រពន្ធវៀតណាមរបស់ខ្លួន ហើយថាបើគាត់មិនសម្លាប់ គេនឹងសម្លាប់គាត់។ ហើយឈ្មោះរបស់គាត់នោះឈ្មោះ ឌឿន ហើយគាត់ក៏មិនឱ្យសម្លាប់កូនទាំងពីរទេ ហើយគេបញ្ជាឱ្យគាត់សម្លាប់ប្រពន្ធគាត់ ហើយ

ដោយយកទៅឆ្ងាយ ហើយឥឡូវនេះ គាត់រស់នៅភូមិ -- ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង ហើយគាត់រស់នៅជាមួយកូនស្រីម្នាក់របស់គាត់ ប៉ុន្តែប្រពន្ធគាត់ស្លាប់ហើយ។ ឈ្មោះ ឌឿន នេះ នៅក្នុងស្រុកបរិបូរខេត្តកំពង់ឆ្នាំង គឺជាស្រុកតែមួយ។ ខេត្តកំពង់ឆ្នាំង គឺជាស្រុក និងខេត្តដដែល ដែល ប្រាក់ ឌឿន នៅ"។

មូលហេតុដែលខ្ញុំធ្វើសេចក្ដីសន្និដ្ឋាននេះ ខ្ញុំចង់ឲ្យមានការបំភ្លឺ ជាពិសេស អំពីសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ថាតើពួកគាត់ដឹងថា បុគ្គលនេះបានយោងទៅរកឯកសារ 3/47372 *(ស៊ីក)* ហ្នឹង គឺថា តើ ប្រាក់ ដែលថា សាក្សីនិយាយពី ឌឿន នោះ តាមពិតជា ប្រាក់ ឌឿន នោះដែរឬទេ។ ក្នុងករណីដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះ យោងទៅរក ប្រាក់ ឌឿន នេះហើយគឺជាអ្វីដែលមេធាវី -- សហមេធាវីនាំមុខដែលជាតំណាងឲ្យកូនក្ដីទាំងពីរហ្នឹង គាត់ពិតជាបានដឹងហើយនៅពេលនោះ ថាអ្នកណាជាអ្នកណា។ ហើយផ្អែកទៅលើចម្លើយ ហើយនិងការបំភ្លឺនេះ ដែលបានផ្ដល់មកឲ្យយើងខ្ញុំ ហើយនិងអង្គជំនុំជម្រះ គឺថាអាចនឹងជួយយើងខ្ញុំនៅក្នុង ឈានដល់ការសម្រេចថាតើត្រូវកោះហៅ ឬមិនត្រូវកោះហៅ ប្រាក់ ឌឿន មកសាជាថ្មី ពីព្រោះថាបញ្ហាថាតើគាត់ខ្លួនឯងពាក់ព័ន្ធក្នុងការសម្លាប់ប្រពន្ធរបស់គាត់ ឬមិនសម្លាប់នោះ គឺទាក់ទងដោយផ្ទាល់ គឺទៅនឹងភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់គាត់ ពីព្រោះថានៅក្នុងសវនាការនេះ គាត់និយាយថាគាត់មិនបានពាក់ព័ន្ធអ្វី គឺថាមនុស្សផ្សេងទេ ដែលជាអ្នកសម្លាប់ប្រពន្ធគាត់នោះ។ ហេតុដូច្នេះ ខ្ញុំសង្ឃឹមថា សេចក្ដីសន្និដ្ឋានរបស់ខ្ញុំ គឺច្បាស់ហើយលោកប្រធាន បាទ។

[០៩:១៩:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយភាគីដទៃទៀត មានអ្វីលើកឡើងបញ្ហានេះទេ សហព្រះរាជអាជ្ញា?

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំមិនមានអ្វីបន្ថែមទេ សំណួរដែលខ្ញុំត្រូវសួរនោះ ថាតើឯកសារដែលមេធាវីការពារក្ដីយោងទៅរកហ្នឹង គឺថាធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍ ថាតើមេធាវីបានទទួលឯកសារហ្នឹងយូរដែរហើយឬនៅ ដែលថាពាក្យសុំតាំងខ្លួនហ្នឹង ដែលថាយោងទៅរកសាក្សីដែលបានមកធ្វើសក្ខីកម្មហ្នឹង តើលោកបានឯកសារហ្នឹង យូរប៉ុន្មានដែរហើយ?

**ប្រធានអង្គជំនុំ៖**

ហើយចុះខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានអ្វី ធ្វើសារណាតបទៅនឹងការលើកឡើងរបស់ -- សូមអញ្ជើញ កុំអាលសិនអ៊ីចឹង!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្អាកសិន!

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមានសំណើមួយទៅកាន់លោកមេធាវី កូប៉េ ដើម្បីឲ្យច្បាស់ទាំងអស់គ្នា។

សំឡេងឮរំខានណាស់លោកប្រធាន។

**អ្នកបកប្រែ៖**

អ្នកបកប្រែស្តាប់ឮ ក៏ប៉ុន្តែសំឡេងរំខានបុកត្រចៀកណាស់លោកប្រធាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលជាបញ្ហានេះមានតែខាងផ្នែកភាសាបារាំងទេមើលទៅ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ចាស លោកចៅក្រម ខ្ញុំក៏ឮអ៊ីចឹងដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខាងខ្ញុំក៏ឮអ៊ីចឹងដែរ ឮសំឡេងបុក។

[០៩:២១:១៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលជាមីក្រូហ្វូនមួយនេះអាចដំណើរការបានល្អជាង។ ខ្ញុំចង់សួរលោកមេធាវី កូប៉េ ដើម្បីឲ្យបានច្បាស់ទាំងអស់គ្នា។ បើតាមខ្ញុំចាំ សាក្សីរូបនោះបានឆ្លើយទៅនឹងសំណួររបស់លោករួចទៅហើយពាក់ព័ន្ធនឹងការដែលសួរ គាត់ថាតើគេមានចោទប្រកាន់គាត់ថា បានសម្លាប់ប្រពន្ធខ្លួនឯងជាជនជាតិវៀតណាម ឬក៏អត់? តើអ៊ីចឹងមែនទេ ពេលហ្នឹងលោកមានបានសួរសំណួរពាក់ព័ន្ធទៅនឹងចំណុចហ្នឹងហើយឬនៅ?

**លោក វិចទ័រ កូប៉េ៖**

កាលណាលោកចៅក្រមអានប្រតិចារឹកហ្នឹង គឺថាសាក្សីនោះបាននិយាយថា គាត់ ហើយអាចនឹងចង្អុលបង្ហាញថា គឺរដ្ឋាភិបាលក្នុងទសវត្សរ៍ឆ្នាំ៨០ ហើយខ្ញុំសួរថា តើគាត់ធ្លាប់ជាប់គុក ឬក៏ទទួលបណ្តឹងអាជ្ញាដែរឬទេ? ពេលនោះ សំណួរទាំងអស់នោះត្រូវបានអង្គជំនុំជម្រះហាមឃាត់ខ្ញុំ។ ដូច្នេះ

ហើយ ខ្ញុំគិតថាសំណួរទាំងអស់នេះផ្អែកទៅលើពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតដែលខ្ញុំបានយល់ហ្នឹង គឺថាគប្បីតែអនុញ្ញាតឲ្យខ្ញុំសួរសំណួរដដែលនោះឡើងវិញ។ តើ ឌឿន ដែលគាត់យោងនេះ តើពិតជា ប្រាក់ ឌឿន ដែលមកធ្វើសក្ខីកម្មពីមុន ដែរឬអត់នោះបាទ?

[០៩:២២:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានលទ្ធភាពក្នុងការធ្វើសារណាតបទៅនឹងសារណារបស់លោកមេធាវី វ៉ិចទ័រ កូប៉េ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំមើលទៅ ដូចជាមិនឃើញមានមូលដ្ឋានអីទេលោកមេធាវីការពារក្តី លោក កូប៉េ នោះ។ ហើយចំពោះយើង ដូចជាមិនចាំបាច់ផ្តល់ព័ត៌មានអីឲ្យគាត់ទេ ហើយប្រសិនបើអង្គជំនុំជម្រះបង្គាប់ឲ្យខ្ញុំផ្តល់ព័ត៌មាន ខ្ញុំនឹងផ្តល់ ក៏ប៉ុន្តែខ្ញុំគិតថាដូចខ្ញុំដូចជាមិនមានសិទ្ធិអីត្រូវឆ្លើយតបទៅនឹងមេធាវីការពារក្តីទេ តែបើអង្គជំនុំជម្រះបង្គាប់ គឺខ្ញុំនឹងធ្វើ។ មេធាវីការពារក្តីត្រូវតែដាក់សំណើថ្មី ផ្អែកតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ គាត់មិនអាចធ្វើអ្វីខុសពីនេះបានទេ។ ខ្ញុំមានការកត់សម្គាល់មួយពាក់ព័ន្ធទៅនឹងឯកសារដែលប្រើប្រាស់នៅថ្ងៃនេះ ដោយមេធាវី កូប៉េ។ ឯកសារនោះ គឺមាននៅក្នុងសំណុំរឿងតាំងពីច្រើនឆ្នាំរួចមកហើយ។ ឯកសារនេះស្ថិតនៅក្នុងឯកសារដែលត្រូវបានស្នើនៅក្នុងបញ្ជីរបស់យើងតាំងពីឆ្នាំ២០១១ តាំងពីពេលចេញដីកាបំបែកនីតិវិធីមកម្ល៉េះ ហើយក៏មាននៅក្នុងបញ្ជីយើងតាំងពីឆ្នាំ២០១៤។ ដូច្នេះភាគីទាំងអស់មានឯកសារហ្នឹងតាំងពីរាប់ឆ្នាំមកហើយ មិនមែនទើបតែទទួលបានឥឡូវនេះទេ ហើយព័ត៌មានដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺវាមិនពាក់ព័ន្ធទៅនឹង ប្រាក់ ឌឿន ទេ គឺនិយាយពីឈ្មោះកា ឌឿន មិនមែន ប្រាក់ ឌឿន ទេ ហើយមានការបញ្ជាក់នៅក្នុងឯកសារថា ប្រពន្ធរបស់គាត់នៅរស់ទេ ហើយ ប្រាក់ ឌឿន គាត់បានប្រាប់យើងថាប្រពន្ធគាត់ស្លាប់ហើយ។ អ៊ីចឹងវាខុសគ្នា។

ដូច្នេះប្រសិនបើជាអង្គជំនុំជម្រះយល់ឃើញថាខ្ញុំត្រូវផ្តល់ព័ត៌មាន ខ្ញុំត្រូវតែផ្តល់តាមក្រោយ។ បើមិនអ៊ីចឹងទេ មេធាវីការពារក្តីត្រូវតែស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីស្តាប់សក្ខីកម្មលោក ប្រាក់ ឌឿន ម្តងទៀត ហើយយើងក៏នឹងឆ្លើយតបជាលាយលក្ខណ៍អក្សរដែរ ទៅតាមសំណើរបស់មេធាវី នួន ជា ផ្អែកតាមវិធាន៨៧(៤)។

[០៩:២៥:៣២]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដថាត្រូវឆ្លើយខ្លីទៅនឹងសហមេធាវីនាំមុខដែរឬអត់ទេ លោកប្រធាន។ ដូច្នេះ អ្វីដែលគាត់យោងទៅនោះ គឺៗបុគ្គលម្នាក់ពិតជាបាននិយាយថា កា ឌឿន បានសម្លាប់ប្រពន្ធទី១របស់គាត់ ដែលថាយកទៅកន្លែងឆ្ងាយ ហើយវាយក្បាលដើម្បីសម្លាប់។ វាទំនងជាស៊ីចង្វាក់ទៅនឹងចម្លើយរបស់ ប្រាក់ ឌឿន ខ្លួនឯងដែលគាត់និយាយថា ខ្ញុំស្បថថាខ្ញុំមិនធ្វើរឿងហ្នឹងទេ។ ខ្ញុំនិយាយថា អ្វីដែលខ្ញុំនិយាយជាការពិត។ ហើយនៅក្នុងពាក្យសុំរបស់ ប្រាក់ ឌឿន នេះគាត់សារភាពខ្លួនឯងគឺថា ហើយវាទំនងជាខ្លឹមសារពាក្យហ្នឹងដដែល ហើយពីមនុស្សដដែល។ អ៊ីចឹងវាទាក់ទងទៅនឹងភាពជឿជាក់បាននៃ ប្រាក់ ឌឿន ក្នុងសក្ខីកម្មរបស់គាត់។ ក្នុង -- យើងមិនមានសិទ្ធិអ្វីក្នុងការបង្ខំឲ្យសហមេធាវីនាំមុខផ្តល់ព័ត៌មាន ឬក៏បញ្ជាក់ថា អ្នកទាំងពីរនាក់នេះជាមនុស្សតែមួយនោះទេ ក៏ប៉ុន្តែខ្ញុំសូមជម្រាបទៅសហមេធាវីនាំមុខថា ក្នុងករណីដែលគាត់ជាមនុស្សតែមួយ ឬក៏ពីរនាក់ហ្នឹង គឺថាវាអាចនឹងជាទំនាស់ផលប្រយោជន៍។ អ៊ីចឹងគឺថាអាចហ្នឹងៗយើងនឹងប្តឹងទៅគណៈមេធាវីរបស់ អូស្ត្រាលី ពីបញ្ហានេះ។ អ៊ីចឹងគឺថាៗ យើងចង់ដឹងថាតើ ឌឿន នេះជា ប្រាក់ ឌឿន ដែរឬអត់។ អ៊ីចឹងគឺថា យើងនឹងពិនិត្យមើលករណីមេធាវីដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះ ថាតើគាត់ធ្វើហ្នឹងទំនាស់ផលប្រយោជន៍ដែរឬអត់។

បាទ សូមអរគុណ។

[០៩:២៧:២៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយខ្លី ដើម្បីពន្យល់អំពីបញ្ហានេះ។ ខ្ញុំគិតថាមានការភ័ន្តច្រឡំហើយត្រង់ចំណុចនេះ។ ការបកប្រែជាភាសាបារាំងនៃពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ គឺ E3/4732 ហ្នឹងគឺ ភាសាបារាំងនិងអង់គ្លេស ខុសគ្នា។ ភាសាបារាំងគេប្រាប់ថា “ស្រី” ៗនៅរស់ ហើយបើភាសាអង់គ្លេសបកថា “ប្រុស” ហើយនៅរស់។ អ៊ីចឹងហើយបានជាខ្ញុំនិយាយថានៅរស់ហ្នឹង ដោយផ្អែកទៅលើការបកប្រែជាភាសាបារាំង។ ដូច្នេះ បើយើងមើលទៅគឺបកប្រែខុសគ្នា ម្នាក់ម្ខាងស្រី ម្ខាងប្រុស។ នេះជាអ្វីដែលខ្ញុំអានតាមរយៈការបកប្រែជាភាសាបារាំងនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់។

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសង្ខេប គឺថាអត្ថបទភាសាអង់គ្លេស គឺថាជាច្បាប់ដើម ដែលត្រៀមឡើង -- ព្រាងឡើង ដោយមេធាវី លីម៉ា ង្វៀន និយាយថាគាត់បានសម្លាប់ប្រពន្ធទី១របស់គាត់ ដោយយកគាត់ទៅកន្លែងណាមួយ ហើយវាយក្បាលរហូតដល់ស្លាប់។ ហើយគាត់នៅរស់ នៅក្នុងស្រុកបរិបូរ។ ឥឡូវនេះ គាត់មានប្រពន្ធមួយទៀតហើយ។ ហើយខ្ញុំសូមឲ្យកោះហៅ ប្រាក់ ឌឿន ឡើងវិញ បាទ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំឯកភាពជាមួយលោក ក៏ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ថា ដែលអម្បាញ់មិញនេះ ខ្ញុំនិយាយថាគាត់នៅរស់ហ្នឹង គឺខ្ញុំផ្អែកលើភាសាបារាំង។ អ៊ីចឹង ការបកប្រែជាបារាំងហ្នឹង គឺវាខុសពីច្បាប់ដើមជាអង់គ្លេស ពាក់ព័ន្ធនឹងការដែលចង់ដឹងថាតើមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សហមេធាវីនាំមុខមានកាតព្វកិច្ចផ្ដល់ព័ត៌មានជូនអង្គជំនុំជម្រះថា តើជាមនុស្សតែមួយឬក៏យ៉ាងណានោះ គឺវាអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេច។ បើអង្គជំនុំជម្រះសម្រេចពិគ្រោះយោបល់ជាមួយយើងខ្ញុំជាផ្លូវការពាក់ព័ន្ធនឹងចំណុចនេះ យើងនឹងផ្ដល់ព័ត៌មានទៅតាមសំណើរបស់អង្គជំនុំជម្រះ។ ក៏ប៉ុន្តែក្នុងពេលទទឹងរង់ចាំនេះ ខ្ញុំគិតថាមេធាវីការពារក្ដីលោក នួន ជា ខ្លួនឯងជាអ្នកត្រូវធ្វើសំណើផ្អែកតាមវិធានផ្ទៃក្នុង៨៧(៤) ដើម្បីឲ្យយើងអាចឆ្លើយតបជាផ្លូវការជាលាយលក្ខណ៍អក្សរ។

[០៩:៣០:០៦]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការលើកឡើងបញ្ហាដែលពាក់ព័ន្ធនេះ ហើយអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យពិចារណាសម្រេចឆាប់ៗនៅពេលសមស្របខាងមុខនេះ ជាពិសេសនៅក្នុងអំឡុងពេលនៃអង្គជំនុំជម្រះដែលមិនធ្វើសវនាការនៅចុងឆ្នាំនេះ។

បាទ តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការជាសាធារណៈស្ដាប់នូវសក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1000 ហើយមុននឹងកោះហៅសាក្សីចូលមកចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានស្ដាប់ចម្លើយនៅក្នុងដំណើរការស៊ើបអង្កេតនៃ -- ដែលកំពុងតែដំណើរការ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើថា សាក្សីរូបនេះគួរប្រើរហស្សនាម ដើម្បីការពារនូវភាពសម្ងាត់នៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតនេះ គឺត្រឹមត្រូវតាមច្បាប់នៅក្នុងករណីបែបនេះ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាព

រវាងតម្រូវការនៃសាធារណភាពនៃសវនាការជាមួយនឹងការការពារសុច្ចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីដែលថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/3 ក្នុងការប្រើប្រាស់ឯកសារដែលដាក់បង្ហាញពីសំណុំរឿង០០៣ និង ០០៤។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការកោះហៅសាក្សី 2-TCW-1000 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៣៣:៤៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! នៅក្នុងកិច្ចដំណើរការសវនាការ--

*(សម្រាករយៈពេលខ្លី)*

[០៩:៣៤:០២]

បាទ អង្គជំនុំជម្រះទើបបានទទួលបានព័ត៌មានថា សាក្សីរូបនេះមានមេធាវីប្រឹក្សាលោក មឿន សុវណ្ណ ដែលគាត់បានស្នើសុំ ហើយអង្គជំនុំជម្រះទើបតែទទួលបានព័ត៌មានអំមិញ ដូច្នេះអង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំនេះ ហើយឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញលោកមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងអង្គុយក្បែរសាក្សីដែលនៅក្នុងបន្ទប់សវនាការនេះ។

*(មេធាវីប្រឹក្សាសាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៣៥:៣៨]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើសុំរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងប្រើតែរហស្សនាមទេ។ លោកសាក្សីគឺមានរហស្សនាម 2-TCW-1000 ក៏ជាទូទៅភាគីតែងតែប្រើប្រាស់ហៅលោកក្នុងនាមថាជាសាក្សីប៉ុណ្ណោះ។ អ៊ីចឹងគឺលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះផងប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

ហើយតទៅនេះ អង្គជំនុំជម្រះសូមសួរបញ្ជាក់ទៅលើអត្តសញ្ញាណមួយចំនួន ដែលមាននៅក្នុង

ឯកសារ E319/23.3.48 ត្រង់ទំព័រទី២។

ក្រឡាបញ្ជីសវនាការយកទៅ -- យកឯកសារទៅបង្ហាញសាក្សីគឺត្រង់ចំណុច *ហាយឡាយ* ដើម្បីបញ្ជាក់អំពីនាមត្រកូល នាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ស្រុកកំណើត មុខរបរ ឪពុកឈ្មោះឪពុក ឈ្មោះម្តាយ ហើយនិងទីលំនៅបច្ចុប្បន្នរបស់លោក ហើយបើត្រឹមត្រូវ ឬខុសត្រង់កន្លែងនោះ សូមលោកបញ្ជាក់ពីចំណុចដែលខុស។ បើត្រឹមត្រូវលោកប្រាប់ឆ្លើយមកអង្គជំនុំជម្រះថាត្រឹមត្រូវតែប៉ុណ្ណោះគឺជាការសម្រេចហើយ។

*(ក្រឡាបញ្ជីយកឯកសារជូនសាក្សី)*

[០៩:៣៧:២០]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីពិនិត្យទៅ ពិនិត្យ -- លោកចេះអក្សរទេ?

**លោក 2-TCW-1000៖**

បាទ ចេះអានបានខ្លះៗបាទ។

**ប្រធានអង្គជំនុំ៖**

មើលអានចំណុច *ហាយឡាយ*ពណ៌លឿងហ្នឹង មើលទៅ ហើយគ្រប់ចំណុចទាំងអស់ តើវាត្រឹមត្រូវដែរឬទេ ហើយបើខុសកន្លែងណាលោកប្រាប់យើងណ៎ះ! ពីចំណុចខុស បើត្រូវគឺប្រាប់ថាត្រូវគ្រប់ចំណុចទាំងអស់ហើយ អាហ្នឹងជាការស្រេចហើយណ៎ះ!

**លោក 2-TCW-1000៖**

បាទ ខ្ញុំអរគុណណាស់ ចំណុចដែលទាំងអស់ ដែលនាមគោលរបស់ខ្ញុំនេះ ឃើញថាត្រឹមត្រូវពិតប្រាកដមែន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្រឡាបញ្ជីសវនាការ នៅពេលនេះយកឯកសារនេះដាក់បញ្ចូលទៅក្នុងសំណុំរឿង។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាម

សមត្ថភាពដែលលោកដឹង គឺលោកមិនមានជាប់ចំណងជាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះទេ។ តើសេចក្តីរាយការណ៍នេះពិតជាត្រឹមត្រូវដែរឬទេ?

[០៩:៣៨:៥៣]

**លោក 2-TCW-1000៖**

**ឆ៖** បាទ ខ្ញុំមិនមានសាច់សាលោកហិតជាប់នឹងអ្វីទេ គឺថាអត់ទាំងអស់បាទ។

**ស៖** ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានធ្វើសម្បថនៅចំពោះអ្នកតាដំបងដែកនៅពីខាងកើតសាលសវនាការនេះហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបានស្បថស្បែគ្រប់សព្វអស់ហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ សាក្សី ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គ-ជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកធ្វើអត្ថាធិប្បាយដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ចក្នុងឋានៈលោកជាសាក្សី ត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការ ត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតបរបស់លោក ឬក៏ការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បាចងចាំមានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគីឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោកសាក្សី តើលោកដែលធ្លាប់ផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ហើយធ្វើនៅទីកន្លែងណា?

[០៩:៤០:៤៨]

**ឆ៖** បាទ ខ្ញុំបាទធ្វើជាពីរដង។ ធ្វើនៅផ្ទះយើងខ្ញុំបានម្តង ហើយធ្វើនៅកំពតនោះបានម្តង។

**ស៖** បាទ អរគុណ។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកសាក្សីបានពិនិត្យមើល ឬក៏បានអាន ឬក៏បានស្ដាប់ការអានន្ធូវសក្ខីកម្មដែលលោកបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតចំនួនពីរដង ដែលលោកអះអាងអំមិញថានៅនឹងផ្ទះរបស់លោក និងនៅទីក្រុងកំពតជាមួយនឹងអ្នកស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានរំឭកនៃការចងចាំរបស់ខ្ញុំបានខ្លះ ហើយមានការភ្លេចភ្លាំងខ្លះបាទ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុដែលស្ដាប់ចម្លើយដែលលោកបានអាន ឬក៏ស្ដាប់ការអានដើម្បីរំឭកការចងចាំនោះពិតជាត្រឹមត្រូវ សមស្រប ស៊ីចង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកបានផ្ដល់ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននៅនឹងផ្ទះរបស់លោក និងនៅទីក្រុងកំពតហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានរំឭកនូវការចងចាំរបស់ខ្ញុំខ្លះ ហើយខ្លះទៀតក៏ចាំបានច្រើន ហើយខ្លះទៀតក៏មានការភ្លេចមួយចំណុចៗអ៊ីចឹងទៅ។

[០៩:៤២:៣០]

**ប្រធានអង្គជំនុំ៖**

បាទ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទបញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គនៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រី ចៅក្រម ភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ជម្រាបសួរលោកសាក្សី។ លោកសាក្សី ប្រសិនណាជាមិនយល់សំណួរខ្ញុំអាចសួរឲ្យខ្ញុំស្នើសុំឲ្យខ្ញុំសួរម្ដងទៀត។ លោកសាក្សី លោកចូលរួមធ្វើជាកងទ័ពនៅពេលណា?

**លោក 2-TCW-1000៖**

**ឆ៖** បាទ ខ្ញុំចូលកងទ័ពនៅតាំងពីឆ្នាំ៧២ រហូតដល់ ឆ្នាំ៧៩។

**ស៖** នៅពេលនោះ តើលោកចូលរួមជាមួយនឹងកងទ័ពមួយណាដែរ? ផ្នែកណាដែរ?

**ឆ៖** បាទ ខ្ញុំចូលធ្វើកងទ័ពដំបូងគឺនៅខាងទ័ពតំបន់ខេត្តកំពត។ ក្រោយមកទៀត ឆ្នាំ៧៥ បានទៅចូលនៅក្នុងកងពល១៦៤។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថាលោកបានចូលធ្វើជាកងទ័ពនៅក្នុងឆ្នាំ១៩៧២ ដើមដំបូងហ្នឹង។ លោកចង់មានន័យថា លោកចូលរួមជាមួយនឹងទាហាន លន់ នល់ ឬក៏យ៉ាងណា?

**ឆ៖** បាទ ជាដំបូងខ្ញុំធ្វើកងទ័ពខាងខ្មែរក្រហម បាទ ខាងកងទ័ព។

[០៩:៤៤:៥៤]

**ស៖** បាទ ខ្ញុំមានចំណាប់អារម្មណ៍រយៈពេលចន្លោះពីឆ្នាំ១៩៧៩ ដល់ ៧៥ សម្រាប់វិសាលភាពនៃការជំនុំជម្រះនេះ។ លោកបានឆ្លើយថានៅក្នុងឆ្នាំ១៩៧៥ លោកធ្វើជាកងទ័ពនៅក្នុងកងពល១៦៤ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវណាស់បាទ។

**ស៖** លោកដឹងថា អ្នកណាជាមេបញ្ជាការកងពល១៦៤ដែរទេ ចន្លោះពីឆ្នាំ៧៥ ដល់៧៩?

**ឆ៖** បាទ ឆ្នាំ៧៩ -- អ៎! ឆ្នាំ៧៥ នោះមិនទាន់ជាប្រកាសនៃការកកងពលទេ ទើបតែឆ្នាំ៧៦ -- ជិតចូល ៧៥នេះ ជិតចូលឆ្នាំ៧៦នេះ ប្រកាសជាកងពលធំគឺ លោកតា មាស មុត តែម្តង គាត់កងពលធំនៅប្រចាំកំពង់សោមតែម្តង។

**ស៖** កងពលនេះ កងពល១៦៤នេះ នៅពេលនោះមានឈ្មោះអីផ្សេងដែរទេ?

**ឆ៖** បាទ តាមការចងចាំរបស់ខ្ញុំ ក្នុងនោះមាន តាសារឿន បាទ។ តាសារឿន និង តាញ៉ាន់ពេលតាមុត -- ពេលនោះទៀតមានកងភូមិភាគបូព៌ា បាទ មានលោក តាឌឹម។ ក្រោយមក តាឌឹម ក៏បាត់ខ្លួនទៅ ខ្ញុំក៏អត់ដឹងដែរ។

[០៩:៤៦:៥៤]

**ស៖** សូមអរគុណ។ ខ្ញុំយល់ថាលោកមិនទាន់ឆ្លើយឲ្យចំសំណួរខ្ញុំទេ។ ខ្ញុំចង់សួរឈ្មោះកងពល១៦៤ហ្នឹង កាលពេលនោះ មុនពេលហៅថាកងពល១៦៤ហ្នឹង តើមានឈ្មោះអ្វីផ្សេងទៀតទេ ឈ្មោះកងពល មិនមែនឈ្មោះមនុស្សទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** ចុះលោកស្គាល់កងពលលេខ៣ដែរទេ?

**ឆ៖** បាទ ស្គាល់ នោះមិនមែនកងពលលេខ៣ គឺថាវរសេនាធំលេខ៣។ ក្រោយមក កងពលនោះ បានចូលជាកងពល១៦៤ តែម្តង។

**ស៖** កងពល១៦៤ ស្ថិតនៅក្រោមការបញ្ជារបស់ មាស មុត លោកថា គឺចន្លោះពីឆ្នាំ៧៦ទៅ។ តើកងពលនោះជាកងពលចំណុះឲ្យភូមិភាគ ឬក៏ជាយ៉ាងម៉េចដែរ ឬក៏ជាកងពលតំបន់?

**ឆ៖** បាទ កងពលនុ៎ងស្ថិតនៅក្នុងកងពលភូមិភាគបូព៌ា -- ភូមិភាគយុទ្ធភូមិភាគ។

**ស៖** ហើយកងពលនេះ បើសិនណាជាចំណុះឲ្យភូមិភាគណាមួយ តើជាកងពលចំណុះឲ្យភូមិភាគណាដែរ?

**ឆ៖** បាទ កងភូមិភាគនេះ គឺមានតែមួយគត់នៅក្នុងយុទ្ធភូមិភាគនៅក្រុងកំពង់សោមតែម្តង។ អត់មានបានទៅណាដែរទេ។

[០៩:៤៩:០៤]

**ស៖** តើលោកធ្លាប់ឮសួរគេហៅថាកងទ័ពមជ្ឈិមដែរទេ?

**ឆ៖** បាទ ឮ ប៉ុន្តែកងទ័ពហ្នឹង ភូមិភាគហ្នឹង យុទ្ធភូមិភាគហ្នឹង គឺជាកងទ័ពមជ្ឈិមតែម្តង។ កងពល១៦៤ហ្នឹង។

**ស៖** ដូច្នេះលោកបានឆ្លើយថា កងពល១៦៤ គឺជាកងពលចំណុះឲ្យមជ្ឈិម អ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនហើយ។

**ស៖** សូមអរគុណ។ គិតចាប់ពីពេលខ្មែរក្រហមរឹបអូសបានទីក្រុងភ្នំពេញ ១៩៧៥ រហូតដល់ពេលវៀតណាមចូលមកដល់ក្នុងឆ្នាំ១៩៧៩។ តើលោកអាចជម្រាបជូនតុលាការបន្តិចបានទេ អំពីតួនាទីរបស់លោកជាហូរហែនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបាទតាំងពីឆ្នាំ៧៥ ដល់រហូតដល់ ឆ្នាំ៧៩ ខ្ញុំបាននៅកងពល១៦៤នោះ វរៈជាវរសេនាតូច៦២២ និងវរសេនាធំ៦២ បាទ នៅប្រចាំពូធីវ៉ៃ។

**ស៖** តើលោកមានតួនាទីអ្វីជាក់លាក់ -- ខ្ញុំរៀបសំណួរឡើងវិញ។ តើលោកអាចពន្យល់បានទេពេលចូលធ្វើកងទ័ពហ្នឹង លោកបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញកងទ័ពពិសេសណាមួយដែរទេ?

**ឆ៖** បាទ អត់មានទេ គឺកងទ័ពនោះ គឺមិនបានទៅហ្វឹកហ្វឺនអ្វីដែល កន្លែងណាដែរទេ បាទ។

សៈ តើលោកប្រយុទ្ធតែលើគោកទេ លោកប្រយុទ្ធក្នុងនាមជាកងទ័ពជើងគោកដែរទេ? ឬក៏លោកប្រយុទ្ធទាំងជើងទឹកផង ជើងគោកផង?

ឆៈ កាលពីឆ្នាំ មុនឆ្នាំ៧៥ ខ្ញុំប្រយុទ្ធនៅលើគោក តែឆ្នាំ៧៥ បានខ្ញុំប្រយុទ្ធនៅក្នុងទឹកតែម្តង។

សៈ មុនពេលលោកចូលធ្វើកងទ័ពជើងទឹកហ្នឹង តើលោកមានបានទទួលការបណ្តុះបណ្តាលដែរទេ?

ឆៈ បាទ ជួបនឹងការបណ្តុះបណ្តាលវគ្គសិក្សា ផ្នែកខាងជើងទឹកហ្នឹងម្តង ពីរដងដែរ បាទ។

សៈ ក្នុងអំឡុងចន្លោះឆ្នាំ៧៥ ដល់ ៧៩ តើលោកបានទទួលការបណ្តុះបណ្តាលខាងនយោបាយដែរទេ?

ឆៈ បាទ អត់មានទេ។

សៈ តើមេបញ្ជាការរបស់លោកធ្លាប់ដែលនិយាយប្រាប់លោកថាខ្មែរក្រហមមានគោលនយោ-បាយ អ្វីខ្លះដែរទេ?

ឆៈ កន្លងមកគាត់អត់មាននិយាយអីទេ គោលនយោបាយលើផ្នែកអ្វីមួយដែរ ខ្ញុំក៏អត់បានដឹងដែរ។

[០៩:៥៣:១៩]

សៈ នៅពេលដែលលោកជាកងនាវិក តើលោកទទួលបញ្ជាពីខាងណាមកដែរ ពេលលោកធ្វើជាកងទ័ពជើងទឹកហ្នឹង?

ឆៈ បាទ ពេលនាវាចរប្រយុទ្ធក្នុង លើក្នុងទឹក បាទ បញ្ជាពីកងពល ទៅវរសេនាធំរបស់ខ្ញុំ។ វរសេនាធំបញ្ជាទៅវរសេនាតូច។ អ៊ីចឹង ខ្ញុំនៅខាងនាវិកនោះ ក៏ទទួលបញ្ជាពីវរសេនាតូច -- អ៊ំ! វរ-សេនាធំទៅ។

សៈ នៅពេលហ្នឹង លោកនៅតែជិះនៅលើកាណូត លើទូកទេឬ នៅពេលដែលលោកដើរល្បាតនៅតាមព្រំដែនទឹករបស់កម្ពុជា?

ឆៈ កាលខ្ញុំនៅលើនាវានោះឃើញថា ពេលយប់ឃើញថា ដើរល្បាតតាមអាដែងព្រំដែន បាទ។

សៈ តើលោកមានបានទទួលបញ្ជាពីខាងណាឲ្យលោកធ្វើអ្វីទេ បើសិនណាជាលោកចេញនាវាល្បាតទៅ ហើយលោកជួបនាវាណាមួយ ឧទាហរណ៍ថា នាវាដឹកជនភៀសខ្លួន ឬក៏អីជាដើម ឬក៏ទូកនេសាទជាដើម តើលោកមានបានទទួលបញ្ជាថា ឲ្យធ្វើយ៉ាងណាចំពោះទូកនេសាទ ឬក៏ទូកអាដែង

អន្ទោប្រវេសន៍ហ្នឹង?

ធ៖ បាទ កាលខ្ញុំនៅខាងនាវាជើងទឹកនោះ បាទ នៅក្នុង ខ្ញុំនៅកង១៤០ គឺថា អត់មានទេ បើកាលនៅខាងជើងទឹកកន្លែងដដែល ប៉ុន្តែនៅថ្នើរជើងខាង វាយនៅលើកោះ អាហ្នឹង បើមានព្រឹត្តិការណ៍អីដែលដូចជាទូកថៃ ទូកអីទៅ ឃើញថា បើគេបញ្ជាឲ្យទៅចាប់ អាហ្នឹងបានទៅចាប់។

ស៖ បាទ សូមថយក្រោយបន្តិច ដើម្បីឲ្យយល់ចម្លើយលោកបានឲ្យច្បាស់។ លោកថា នៅពេលដែលលោកនៅលើកោះហ្នឹង គឺថាលោកមានទទួលបញ្ជាពីមេបញ្ជាការ។ តែដំបូង សូមៗបញ្ជាក់សិនថា កោះដំបូងដែលលោកឈរជើងនៅហ្នឹង កោះឈ្មោះអ្វីដែរ?

ធ៖ បាទ កោះដំបូងបំផុត គឺកោះតាង បន្ទាប់ពីកោះតាងមក បានខ្ញុំទៅនៅកោះពូធីវ៉ៃ។

ស៖ នៅពេលដែលលោកនៅលើកោះតាង និងកោះពូលូវ៉ៃហ្នឹង ក្នុងឆ្នាំណាដែរ?

ធ៖ បាទ ឆ្នាំ៧៥ ខ្ញុំនៅកោះតាង។ ៧៦ ខ្ញុំចូលទៅនៅកោះពូធីវ៉ៃ។

ស៖ នៅ -- តើលោកនៅលើកោះពូលូវ៉ៃ អស់រយៈពេលប៉ុន្មានដែរ?

[០៩:៥៦:៥៣]

ធ៖ អស់រយៈពេលបានឆ្នាំ៧៧ បានខ្ញុំចាកចេញពីកោះពូធីវ៉ៃនោះដែរ។

ស៖ ហើយក្រោយឆ្នាំ១៩៧៧ លោកទៅទីណាទៀត?

ធ៖ បាទ ខ្ញុំ៧៧ បានអង្គការចាត់តាំងឲ្យខ្ញុំមកនៅកងជើងទឹក នាវា នាវិកប្រដេញ។

ស៖ តើលោកមានមូលដ្ឋានឈរជើងនៅកន្លែងណាដែរនៅពេលលោកនៅជានាវិកប្រដេញហ្នឹង?

ធ៖ បាទ ខ្ញុំកាលនោះ ឈរជើងនៅផែអូរឈើទាលតែម្តង។

ស៖ នៅពេលលោកឈរជើងនៅផែអូរឈើទាល តើលោកចេញទៅល្បាតដែរទេ ជិះនាវាល្បាតមើលដែនទឹកហ្នឹងដែរទេ?

ធ៖ បាទ នាវាទាំងអស់ នាវាចម្បាំងនោះ គឺថាអត់ចេញការពារទេ តែមាននាវាមួយចំនួនដេញចេញទៅការពារ។ បើមានព្រឹត្តិការណ៍អីកើតឡើង បានបញ្ជានាវានោះទៅប្រយុទ្ធតែម្តង។

ស៖ តើលោកមានបានទទួលបញ្ជាឲ្យបញ្ឈប់ទូក ឬកប៉ាល់ណាមួយទេ? តើមានបញ្ជាឲ្យបញ្ឈប់ ឬក៏ឲ្យបាញ់ពន្លិចទូក ឬកប៉ាល់ណាមួយទេ?

ធ៖ បាទ នៅក្នុងពេលនោះ ដែលទាន់មិនទាន់មានវៀតណាមចូលមក ឃើញថា ខ្ញុំគ្មានបានទទួលបញ្ជាពីថ្នាក់ណាដែរទេទាំងអស់ អត់ទេទាំងអស់។

**ស៖** ដូច្នេះលោក គឺជាកងទ័ពជើងទឹកម្នាក់ គឺថាមិនដែលធ្លាប់បានទទួលបញ្ជាពីអ្នកណាម្នាក់ទេ លោកធ្វើអីតាមតែចិត្តរបស់លោកចង់ធ្វើ។ លោកចង់ថាអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទអត់ទេ គឺទាល់តែបញ្ជាពីថ្នាក់លើ បានខ្លួនបុគ្គលខ្លួនខ្ញុំបានចេញ។ បើថាអត់មានបញ្ជាទេ គឺថាមិនហ៊ានអនុវត្ត។

**ស៖** តើលោកទទួលបញ្ជាពីថ្នាក់លើឲ្យលោកចេញទៅក្រៅ ចេញទៅល្បាតជាដើមហ្នឹង នៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំអត់បានទទួលអាដែងខាងទៅល្បាតទេ ប៉ុន្តែមានក្រៅពីនោះ អ្នកល្បាតផ្សេង ហើយនាវិកដែលនៅលើនាវិកនោះ គឺអត់មានបានទៅណាទេ លុះត្រាណាដែលមានឧប្បត្តិហេតុកើតឡើង អាហ្នឹងបានគេបញ្ជាឲ្យនាវិកនោះចេញធ្វើប្រតិបត្តិ។

[១០:០០:៤៦]

**ស៖** តើលោកធ្លាប់ដែលបានបញ្ជាឲ្យបញ្ឈប់កប៉ាល់ កាណូតណាមួយទេ ហើយបើគេមិនឈប់ទេ មានបញ្ជាថាឲ្យបាញ់ពន្លិចទូក កប៉ាល់ទាំងនោះទេ?

**ឆ៖** បាទ នៅក្នុងពេលនោះ ខ្ញុំអត់មានដែលជួបប្រទះ ពេលគេបញ្ជាឲ្យទៅបញ្ឈប់កប៉ាល់ណាមួយ ឬមួយថាបាញ់កប៉ាល់ណាមួយ គឺថាអត់ទេ អត់មានទាន់បានជួបអីទាំងអស់។

**ស៖** លោកបាននិយាយថា លោកត្រូវបានគេសម្អាសម្តងនៅកំពត ហើយកិច្ចសម្អាសន៍នោះ គឺថាសម្អាសដល់ទៅប្រាំថ្ងៃឯណោះ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ អត់ទេ បានតែបីថ្ងៃទេ សម្អាសនៅកំពតហ្នឹង។

**ស៖** ហើយលោកបានឆ្លើយថា លោកបានអានកំណត់ហេតុស្តាប់ចម្លើយនោះឡើងវិញហើយ ខ្ញុំចង់អានចម្លើយមួយ ដែលលោកបានឆ្លើយនៅថ្ងៃទី២ E319/23.3.44 សំណួរចម្លើយលេខ២៦ លោកបានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតថា៖ "បើសិនណាជាយើង -- គេបញ្ជាឲ្យយើងបញ្ឈប់កាណូតណាមួយ តែគេមិនស្តាប់បញ្ជាយើងនោះ យើងអាចបាញ់ពន្លិចតែម្តង។ ខ្ញុំមិនដែលឃើញ បានកាណូតដោយខ្លួនឯងទេ តែអ្នកនៅក្នុងអង្គភាពរបស់ខ្ញុំធ្លាប់បានបាញ់ពន្លិចកាណូត ហើយបាញ់ពន្លិចនេះ គឺជាបញ្ជាអនុវត្តទូទៅរបស់កងពល"។ ហើយចម្លើយ២៧ លោកថា៖ "វាបញ្ជាទូទៅរបស់កងពលទៅគ្រប់ផ្នែកទាំងអស់ បញ្ជានេះ គឺចេញពីកងពល ចុះទៅកងវរសេនាតូច"។ តើចម្លើយទាំងពីរនេះ ត្រឹមត្រូវដែរឬទេ ចម្លើយដែលទើបតែអានឲ្យលោកស្តាប់អម្បាញ់មិញនេះ?

**ឆះ** បាទ ចម្លើយនេះគឺថាបញ្ជាពីវរសេនាធំ -- អំ! ពីកងពលទៅវរសេនាធំ។ វរសេនាធំបញ្ជាទៅអនុសេនាតូច បាទ។ ចម្លើយនេះឃើញថាបានត្រឹមត្រូវ។

**សះ** នៅពេលដែលគេបញ្ឈប់កាណូតណាមួយ តើកងកម្លាំងនៅក្នុងអង្គភាពរបស់លោកត្រូវរាយការណ៍ទៅថ្នាក់លើដែរទេ ថាតើមានអ្នកណា ជនជាតិអ្វី ប្រជាជនណាដែលនៅកាណូតនោះ ដែលត្រូវរាយការណ៍ទៅថ្នាក់លើដែរទេ?

**ឆះ** បាទ បើមានការចាប់កប៉ាល់ ដូចជាកប៉ាល់ថៃបានអ៊ីចឹង ត្រូវតែរាយការណ៍។ បាទ រាយ-ការណ៍ទៅវរសេនាតូច វរសេនាតូចរាយការណ៍ទៅវរសេនាធំ វរសេនាធំរាយការណ៍ទៅកងពល បាទឲ្យដឹង។

[១០:០៥:២៥]

**សះ** សំណួររបស់ខ្ញុំសួរថា តើលោកត្រូវរាយការណ៍ទៅវរសេនាធំ ទៅកងពល ឧទាហរណ៍ថានៅលើកាណូតហ្នឹងមានជនភៀសខ្លួនជនជាតិវៀតណាម ឬក៏អ្នកនេសាទអីជាដើម។ល។ហ្នឹង លោកត្រូវរាយការណ៍ទៅថ្នាក់លើទេ?

**ឆះ** បាទ រឿងនេះ រាយការណ៍ជាបន្តបន្ទាប់ អត់មាន អត់រាយការណ៍ទេ។ បើចាប់យួន ប្រាប់ថាយួន បើចាប់ថៃ នេសាទថៃ អាហ្នឹងប្រាប់ថា នេសាទថៃ។ បាទ រាយការណ៍ច្បាស់ៗទៅ ជូនវរសេនាតូច វរសេនាតូចរាយការណ៍ការទៅវរសេនាធំ វរសេនាធំរាយការណ៍ទៅកងពលជាបន្ទាន់។

**សះ** តើនៅពេលដែលលោករកឃើញថាមានប្រជាជនវៀតណាមនៅលើទូក តើមានបញ្ជាឲ្យលោកធ្វើយ៉ាងម៉េច ចាត់ការយ៉ាងម៉េចដែរជាមួយប្រជាជនវៀតណាមនៅទូកនុ៎ង?

**ឆះ** បាទ កន្លងមកខ្ញុំមិនទាន់មានការអនុវត្តទេ ប៉ុន្តែក្នុងអង្គភាពរបស់ខ្ញុំមានការអនុវត្ត បាទ ដូចជាជនជាតិវៀតណាម បាទ។ បើបញ្ជាពីកងពលឲ្យបញ្ជូនទៅដីគោក ហ្នឹងទៅដីគោក បាទ យកទៅដីគោក ត្រង់គេបញ្ជូនទៅណាទៀតក៏ខ្ញុំអត់បានដឹងដែរ។

**សះ** ចម្លើយបន្ទាប់នៅក្នុងឯកសារ នៅក្នុងបទសម្ភាសន៍ដែលខ្ញុំនិយាយ គឺនៅចម្លើយទី២៩ លោកនិយាយថា៖ "បញ្ជាគឺប្រាប់ច្បាស់លាស់ណាស់ តើត្រូវសម្លាប់នៅនឹងកន្លែង ឬក៏បញ្ជូនទៅលើគោក ប្រសិនបើអ្នកណាដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុ មុននឹងគេសម្លាប់អ្នកទាំងនោះ។" តើត្រឹមត្រូវដែរឬទេ ថាលោកបានដឹងរឿងនេះ?

**ឆ៖** បាទ រឿងនោះ ជាពិតប្រាកដមែន។

**ស៖** អ៊ីចឹង បញ្ហាក្នុងការសម្លាប់មនុស្សនៅនឹងកន្លែង តើអ្នកណាជាអ្នកបញ្ជា -- តើលោកទទួលបញ្ជាឲ្យសម្លាប់អ្នកណាខ្លះ ដែលថាត្រូវសម្លាប់នៅកន្លែងដែលឃាត់បាននោះ?

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងអីទេ ព្រោះដឹងបើថាគេឲ្យចាប់ដឹងថាចាប់។ បើថារឿងសម្លាប់អី បាទ ខ្ញុំមិនទាន់បានប្រព្រឹត្តដោយខ្លួនឯងទេ បាទ។

[១០:០៧:៣៧]

**ស៖** លោកនិយាយថា ទាហានវៀតណាមមួយចំនួនត្រូវបានយកទៅ ហើយគេផ្សាយចម្លើយសារភាពរបស់ពួកគេនៅតាមវិទ្យុមុននឹងគេសម្លាប់អ្នកទាំងអស់នោះ។ តើគេកត់ត្រាចម្លើយសារភាពទាហានវៀតណាមទាំងអស់នោះ គេកត់ត្រានៅកន្លែងណា?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ អស់លោក។

**ស៖** នៅក្នុងៗផ្នែកទី១ នៅក្នុងរឿងក្ដី០០២/០១ គឺថ្ងៃទី០១ មេសា ឆ្នាំ២០១២ មេបញ្ជាការនៃ ស-២១ ឈ្មោះ ឌុច បានធ្វើសក្ខីកម្មថា នៅម៉ោង០៩:៥៩ ពេលព្រឹក ហើយគាត់បាននិយាយក្នុងភស្តុតាងថា នួន ជា បានសុំឲ្យ ស-២១ កត់ចម្លើយ កត់ត្រាចម្លើយសារភាពជនជាតិវៀតណាមពីរនាក់ដើម្បីចាក់ផ្សាយតាមវិទ្យុមួយអាទិត្យ។ ហើយគាត់ឆ្លើយថា៖ "សូមអរគុណលោកប្រធាន គឺថានៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៩ នួន បានហៅខ្ញុំឲ្យទៅធ្វើការ ហើយក្រោយពីការប្រជុំ ហើយនិងជោគជ័យរបស់ទ័ពបដិវត្តកម្ពុជាលើវៀតណាម ហើយ នួន បានបង្គាប់ឲ្យយើងខ្ញុំកត់ត្រាចម្លើយសារភាពរបស់ទាហានវៀត-ណាម"។ តើលោកសាក្សីធ្លាប់ឮពីការចាក់ផ្សាយបទ -- ចម្លើយសារភាពរបស់អ្នកណាម្នាក់ដែលលោកបានចាប់ខ្លួនមកពីដែនសមុទ្រដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់មានបានដែលដឹង អត់ដែលឮទេ បាទ។

**ស៖** បាទ តើមានអ្វីកើតឡើងចំពោះដែលគេចាប់បាននៅលើកាណូតទាំងជនជាតិវៀតណាមជាជនភៀសខ្លួន? តើគេយកជនជាតិវៀតណាមជាជនភៀសខ្លួនទៅសម្លាប់ ឬក៏យកមកលើគោកដែរ?

បាទ ខ្ញុំសូមរៀបសំណួរឡើងវិញលោកសាក្សី។ ជាដំបូង តើខ្លួនលោកផ្ទាល់ធ្លាប់ចាប់បានកាណូតដែលមាន មនុស្សនៅលើកាណូតនោះដែរទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំបាន -- អត់ដែលបានចាប់ផ្ទាល់ដោយខ្លួនឯងទេ បាទ។

[១០:១០:៣៤]

**ស៖** នៅពេលដែលលោកពាក់ព័ន្ធក្នុងការចាប់ខ្លួនជនភៀសខ្លួនវៀតណាមកាលនោះ តើលោកមានពាក់ព័ន្ធអ្វីដែរទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** តើលោកធ្លាប់ទៅតាមកាណូត ឬក៏ទៅតាមនាវា ហើយទៅចាប់បានកាណូតរបស់ជនជាតិវៀតណាម ហើយជាមួយនឹងកងកម្លាំងរបស់លោកដែលថា មានពិការដៃផងដែរនោះ តើលោកធ្លាប់បានពាក់ព័ន្ធក្នុងរឿងហ្នឹងទេ?

**ឆ៖** បាទ នៅពេលនោះ ខ្ញុំនៅកងនាវិកហើយ តែពេលដែលគេចាប់បាន ដែលជនជាតិវៀត-ណាមមានពីរនាក់ពិការដៃនោះ ខ្ញុំបានឃើញផ្ទាល់ក្នុងភ្នែករបស់ខ្ញុំនៅផែអូរឈើទាល ដែលគេចាប់បញ្ជូនមកទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញាអន្តរជាតិ។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សីក្នុងឋានៈលោកជាសមាជិកកងទ័ពជើងទឹកនៃរបបខ្មែរក្រហម តើលោកអាចបដិសេធមិនគោរពតាមការបញ្ជាណាមួយបានទេ?

**លោក 2-TCW-1000៖**

**ឆ៖** បាទ ខ្ញុំមិនអាចបដិសេធបានទេ បើបញ្ជាការ បញ្ជាមកហើយ គឺថាអ្វីក៏ដោយគឺមិនអាចមិនធ្វើបានទេ។

**ស៖** តើមានអ្វីកើតឡើងចំពោះអ្នកដែលមិនគោរពតាមបញ្ជា?

[១០:៣៤:៤៥]

**ឆ៖** បាទ បើអ្នកមិនគោរពតាមបញ្ជារបស់គេ គឺថាត្រូវមានបញ្ហាដោះស្រាយនៅពេលក្រោយ។

**ស៖** លោកចង់និយាយថាម៉េច ពេលថាត្រូវមានបញ្ហាដោះស្រាយពេលក្រោយនោះ?

**ឆ៖** បាទ ត្រូវមានការដោះស្រាយ បើគេមិនចាប់ខ្លួន ក៏គេយកទៅអប់រំកន្លែងណាមួយ។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកគឺឯកសារ E319/23.3.44 ត្រង់ចម្លើយ៣៦ លោកបានឆ្លើយដូចតទៅ៖ "បាទ គឺមកទាល់ថ្ងៃនេះ គេបានប្រាប់ខ្ញុំថាក្នុងចំណោមអ្នកទាំងអស់នោះ គឺមានម្នាក់ដាច់ដៃម្ខាង"។ លោកចាំថាពេលនោះ គឺលោកបានដឹកមនុស្ស១២ទៅ១៣នាក់ដែលលោកចាប់បានកប៉ាល់មួយ ហើយក្នុងនោះ ក្នុងចំណោម១២ទៅ១៣នាក់ហ្នឹង មានម្នាក់ដាច់ដៃម្ខាង។ លោកចាំរឿងហ្នឹងទេ?

**ឆ៖** បាទ រឿងនេះខ្ញុំនៅចាំត្រង់ថា ទៅចាប់យកមកហើយ ខ្ញុំបានឃើញព្រឹត្តិការណ៍ដែលកើតឡើង ដោយគេវាយតប់ មុននឹងពេលគេយកឡានមកដឹកចេញពីផែអូរឈើទាល។

**ស៖** ប្រជាជនទាំងអស់នេះជាកងទ័ពដែលមានកាន់អាវុធ ឬក៏ជាអ្នកណា?

**ឆ៖** បាទ បើតាមចម្លើយសួរទៅជនជាតិវៀតណាមនៅលើទូកនោះ អ្នកពិការដៃនោះ គឺជាទាហាន ក្រៅពីនោះជាប្រជាជន តែសួរវាថាទៅណា? វាថាទៅរត់ទៅប្រទេសថៃតែម្តង។ ក្រោយមកបានយើងឃើញ យើងចាប់នៅចន្លោះកោះពូធីវ៉ៃ និងកោះតាង ចាប់មកយកផែអូរឈើទាលនេះបានជួបខ្ញុំផ្ទាល់។

**ស៖** តើអ្នកទាំងអស់នេះមានកាន់អាវុធ ហើយមានការប៉ុនប៉ងចង់តដៃអីដែរទេ?

**ឆ៖** បាទ គ្មានទេ គ្មានអាវុធទេ។

**ស៖** មានកុមារម្នាក់គឺថាជាៗទារកម្នាក់ក្នុងហ្នឹង លោកចាំទេ?

**ឆ៖** បាទ ខ្ញុំចាំ។ ក្នុងនោះ ពេលយកទៅដល់ផែអូរឈើទាលនោះ ឃើញថាក្មេងនោះមានការយំស្រែកយ៉ាងខ្លាំង ដោយម្ដាយវាចាប់ចង ក្រោយមកវាក្មេងនោះក៏ហៅអ៊ឹម។ ក្រោយមកក៏ឃើញយោធាចាប់កូនក្មេងនោះបោះទម្លាក់ទឹកចោលតែម្ដង។

**ស៖** សូមអរគុណ។ នៅពេលលោកធ្វើការនៅកំពង់ផែអូរឈើទាល លោកដឹងថាគេចាប់បានជនជាតិវៀតណាមប៉ុន្មាននាក់ដែរ នាំយកមកផែអូរឈើទាលហ្នឹង?

**ឆ៖** បាទ ក្នុងពេលឆ្នាំ៧៧នោះ ឃើញថាខ្ញុំបានឃើញមួយដង ទៅពីរដងដែរ ប៉ុន្តែក្រោយៗមកឃើញថាមិនមានសកម្មភាពអីធ្វើបាបនៅលើផែទេ ឃើញថាមកដល់ផែនោះ ឃើញថាភាគច្រើនឡានគេដឹកបញ្ជូនចេញយកទៅក្រុងកំពង់សោមតែម្ដង។

**ស៖** អ្នកដែលគេយកមកកន្លែងលោកហ្នឹង គេបញ្ជូនទៅឯណាដែរ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំនៅខាងនាវិក នៅប្រចាំនៅកំពង់ផែនោះបាទ។

[១០:៣៩:៥៩]

**ស៖** ខ្ញុំហាក់មានភាពច្របូកច្របល់បន្តិច ដោយសារចម្លើយរបស់លោកនៅក្នុងឯកសារ E319/23.3.46 ត្រង់ចម្លើយលេខ៩ គេបានសួរ៖ “តើលោកធ្វើការនៅផែអូរឈើទាលអស់រយៈពេលប៉ុន្មាន? លោកឆ្លើយថា៖ ខ្ញុំធ្វើការនៅអូរឈើទាលនោះពេញឆ្នាំ១៩៧៨ រហូតដល់វៀតណាមចូល ហើយបន្ទាប់មកទៀតថា តើគេបញ្ជូនមនុស្សចេញពីអូរឈើទាលប៉ុន្មានដងដែរ ហើយម្ដងៗពេលគេនាំមនុស្សមកចូលអូរឈើទាលមានប៉ុន្មាននាក់? ចម្លើយលេខ១០ លោកឆ្លើយថា៖ មនុស្សដែលគេចាប់បានគឺមានចំនួនរាប់ពាន់នាក់ បើតាមខ្ញុំដឹង ហើយក្នុងមួយខែៗ គេបញ្ជូនមនុស្សតាមផែអូរឈើទាលច្រើនជាងពីបួនទៅប្រាំដង។ ហ្នឹងតាមដែលលោកមានបទពិសោធន៍ធ្វើការនៅក្នុងអង្គភាពកងទ័ពជើងទឹកចន្លោះពីឆ្នាំ៧៥ទៅដល់៧៩ ហើយក៏សួរថា៖ តើជនភៀសខ្លួន និងអ្នកនេសាទ បានចូលមកដល់ដែនទឹកកម្ពុជាគឺថា ត្រូវបានគេចាប់និងសម្លាប់ដែរទេ? លោកថា៖ រាប់ពាន់នាក់ឯណោះ រួមទាំងអ្នកនេសាទជនជាតិវៀតណាម ថៃ និងជនភៀសខ្លួនត្រូវបានគេចាប់ខ្លួន គេយកមកសម្លាប់ចោលនៅលើកោះ ឬក៏មកសម្លាប់ចោលនៅលើដីគោក។” តើត្រឹមត្រូវដែរឬទេអ្វីដែលខ្ញុំទើបអានឱ្យលោកស្ដាប់នេះ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ប៉ុន្តែខ្ញុំសូមអភ័យទោសចុះ បាទ ដោយបាន ខ្ញុំមិនបានរំឭកអស់រឿងរ៉ាវអស់ទាំងនេះ។ តាំងពីឆ្នាំ៧៧ រហូតដល់ឆ្នាំ៧៨ ព្រឹត្តិការណ៍នេះ ដែលកើតច្រើនៗ ដែលចាប់បាន

បាទ។ អ៊ីចឹងឃើញថា បញ្ជូនមកជាបន្តបន្ទាប់ ពេលនុ៎ងក្នុងប្រជាជនថៃ ជាជននេសាទត្រី និងជនជាតិវៀតណាមដែលរត់ឆ្លងដែនទៅប្រទេសថៃជាច្រើន។ បាទ ខ្ញុំសម្ដែងនូវការស្មោះត្រង់ ដោយពិតប្រាកដពេលនោះ យកទៅសម្លាប់ចោលតែម្ដង អត់មានបញ្ជូនទៅណាទេ ក្នុងពេលនោះ។

**ស៖** លោកសាក្សី លោកដឹងថា អ្នកដែលគេចាប់បាននេះ គេនាំមកលើដីគោក គេសម្លាប់នៅត្រង់ណា គេកប់ចោលនៅត្រង់ណាដែរ?

**ឆ៖** បាទ កន្លងមកដែលនៅកន្លែងនោះ ឃើញថា ខ្ញុំមិនបានឡើងទៅទេបាទ។ នៅកន្លែងនោះនៅផែអូរឈើទាលនុ៎ង ឃើញថាមានគេដឹកយកទៅ ថាដឹកទៅក្រុងកំពង់សោម ប៉ុន្តែរឿងសម្លាប់ៗទាំងអស់ ប៉ុន្តែអត់ដឹងកន្លែងចំណុចនៃសម្លាប់ទេ។ បាទ នៅក្នុងពេលនោះ កន្លែងអាដែងកំពង់សោម តែក្រៅពីកន្លែងកំពង់សោមនោះ ដូចជា ចម្ការក្រូច ចម្ការទុរេនអីមួយចំនួនទៀត ហ្នឹងយើងខ្ញុំអាចបានដឹងខ្លះបាទ។

[១០:៤៣:៣៦]

**ស៖** សូមអរគុណលោកសាក្សី។ ធ្វើម៉េចបានជាលោកដឹងថា អ្នកដែលគេចាប់បានទាំងនោះត្រូវបានគេយកទៅសម្លាប់ចោលនៅក្នុងចម្ការដូង?

**ឆ៖** បាទ នៅក្នុងឆ្នាំ៧៦-៧៧នុ៎ង ពេលនោះ ខ្ញុំបានធ្លាប់ទៅរស់នៅក្នុងក្បែរចម្ការក្រូច ដោយមូលហេតុដែលខ្ញុំជាប់និន្នាការមិនល្អ ពេលនោះគេបញ្ជូនខ្ញុំឱ្យទៅធ្វើស្រែចម្ការ ធ្វើស្រែនៅជិតវាម។ បាទ ពេលនុ៎ងឃើញថា សភាពការណ៍ដែលគេយកទៅសម្លាប់នោះ ភាគច្រើននៅកងពលដែលខ្ញុំធ្លាប់រស់នៅពីមុនបាទ។ ពីមុនមកខ្ញុំនៅកងពលវរសេនាធំ៦២ បាទ ពេលនុ៎ងវរសេនាធំ៦២នោះ គេចាប់បានគេបញ្ជាឱ្យយកទៅចម្ការក្រូច និងចម្ការដូង យកទៅសម្លាប់ចោលនៅទីនោះ ហើយគេយកសាកសពនោះធ្វើជាជីតែម្ដង។

**ស៖** សូមអរគុណ។ អ្នកដែលគេសម្លាប់ហើយយកសាកសពហ្នឹងទៅធ្វើជីហ្នឹងជាអ្នកណា? ជាប្រជាជនបែបម៉េចដែរ? ប្រភេទណាដែរ?

**ឆ៖** បាទ ជាទូទៅឃើញថា ថៃ និង វៀតណាមតែម្ដង។

**ស៖** លោកមិនពាក់ព័ន្ធក្នុងការសម្លាប់ទេ ប៉ុន្តែ តើលោកធ្វើម៉េចបានជាលោកដឹងអំពីការសម្លាប់ទាំងអស់នេះ?

**ឆ៖** ព្រឹត្តិការណ៍នេះដែលកើតឡើង ខ្ញុំរស់នៅជិតនោះៗ ហើយជីវប្រវត្តិរបស់ខ្ញុំនៅវរសេនាធំ

៦២ នេះជាកងវរៈចាស់របស់ខ្ញុំ។ អ៊ីចឹងហើយកូនទាហានដែលខ្ញុំធ្លាប់ស្គាល់ ហើយធ្លាប់រស់នៅជាមួយគ្នា ស្គាល់គ្នាមកឃើញថា គេនៅទីនោះ ខ្ញុំបានសាកសួរដោយស្មោះត្រង់ ដែលយោធានោះឃើញថាគឺសម្លាប់ពិតប្រាកដមែន។

[១០:៤៦:២៣]

**ស៖** សូមលោកជួយពន្យល់ជូនតុលាការសង្ខេបបន្តិចមក ហេតុអីបានជាគេមិនដាក់វិន័យ ដាក់ទណ្ឌកម្មលោក?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំពេលនោះខ្ញុំនៅកងពល១៦០ វរសេនាធំ៦២ ដោយគេមានវិន័យដោយលែងទុកចិត្តខ្ញុំជាយោធាល្អម្នាក់នៅក្នុងអង្គភាព ដោយសារមូលហេតុថា ក្រុមរបស់ខ្ញុំ១២នាក់ បាទ១២នាក់ដែលជាក្រុមអារឈើ។ ពេលនោះ គាត់ក៏មានចេញជាសកម្មភាពដែលមិនគប្បី សរសេរពាក្យស្លោកថា "ជាទមិឡៗកុម្មុយនីស្ត"។ ពេលនោះ ក្រោយមកក៏គេចាប់ ក៏គេវរសេនាតូចម្នាក់ដែលគេទៅត្រួតពិនិត្យនៅការអារឈើនោះ គេឃើញៗអក្សរនេះ រួចហើយក៏គេហៅយើងខ្ញុំនិងក្រុមទាំងអស់គ្នានោះទៅនៅកន្លែងវរសេនាតូច។ ពេលនោះគេសួរពីណាសរសេរ ហើយពីណាខ្លះសរសេរពាក្យស្លោកនេះ។ បាទ កាលនោះ ខ្ញុំមិនចេះអក្សរទេប្រាប់អស់លោកត្រង់ គ្មានចេះអក្សរទេ។ ពេលនោះ ខ្ញុំអត់បានចូលរួមនៅពាក្យស្លោក សរសេរពាក្យស្លោកនោះទេ។ អ៊ីចឹងក្រុមរបស់ខ្ញុំដែលប្រាំប្រាំមួយនាក់ គាត់ជាអ្នកសរសេរ។ ពេលនោះក៏គេចាប់ខ្លួនទាំងអស់ – ចាប់ខ្លួនទាំងអស់។ ក្រោយមកទៀត ខ្ញុំគេដកសេចក្តីទុកចិត្តជាជនសង្ស័យ ជាជនដែលមិនល្អនៅក្នុងកង ក៏គេដកខ្ញុំទៅនៅចម្ការក្រូចឲ្យធ្វើស្រែតែម្តង។

**ស៖** គេប្រើពាក្យនេះ ហ្នឹងគេប្រើពាក្យថា "បិសាច" ប្រើពាក្យថា "នរក" អ៊ីចឹងត្រឹមត្រូវដែរទេ? គេពាក្យស្លោកដែលលោកថាហ្នឹង ពាក្យថា "ទមិឡ នរក" អ៊ីចឹងឬក៏យ៉ាងណា?

[១០:៤៨:៥២]

**ឆ៖** បាទ មិនមែនទេ ពាក្យដែល "ទមិឡ" គឺហៅថា "ទមិឡកុម្មុយនីស្ត" បាទ ជាទមិឡកុម្មុយនីស្តនេះជាបំភ្លើស បំភ្លៃនៃច្បាប់របស់គេ។ អ៊ីចឹងហើយបានគេចាប់អ្នកទាំងអស់នោះយកទៅដាក់គុកនៅទឹកសាបតែម្តង ហើយខ្លួនខ្ញុំគេដកសេចក្តីទុកចិត្ត យកខ្ញុំទៅដាក់ឲ្យធ្វើស្រែដោយជាជនសង្ស័យ ជាកា.ហ្សេ.បេ របស់យួន។

**ស៖** សូមអរគុណ។ ក្នុងអំឡុងពេលនោះ ដែលលោកស្ថិតនៅជាជនសង្ស័យនៅរាម។ លោកមានបានដឹងអំពីជោគវាសនារបស់ប្រជាជន១៧មេសា ដែលរស់នៅតំបន់នោះទេ?

**ឆ៖** បាទ អរគុណណាស់ រឿងរ៉ាវអស់ទាំងនេះ ខ្ញុំបានដឹងនូវប្រជាជន១៧មេសា នៅភូមិគគីរស្នាច់ដែង ពុតទេ ដែលដកពីរាម ដកពីកងកេង បាទ យកប្រមូលផ្តុំនៅភូមិគគីរ។ នៅស្នាច់ដែងនេះឃើញថា បានដឹងព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំ៧៧ ចុងឆ្នាំ៧៧នេះ។ បាទ ប្រជាជននេះ ដោយសារដែលខ្ញុំដឹង ព្រោះខ្ញុំគេឲ្យធ្វើស្រែជាមួយប្រជាជន១៧មេសា តែខ្ញុំធ្វើស្រែចម្ការ ធ្វើស្រែជាមួយប្រជាជន១៧មេសានុ៎ង ថ្ងៃមួយ ថ្ងៃក្រោយមក ខ្ញុំចេះតែឃើញបាត់អស់ទៅៗ ខ្ញុំមានការសង្ស័យ មិនដែលឃើញប្រជាជននោះបានមកចូលរួមធ្វើការងារជាមួយគ្នាទៀត ក៏ខ្ញុំបានសួរទាហានយោធាម្នាក់ដែលឃ្លាលទានៅលើថ្នល់នោះ ជិតភូមិគគីរនោះ។ ខ្ញុំបានស្គាល់គ្នាហើយ ខ្ញុំបានសួរ “មិត្ត! ប្រជាជនដែលអ្នកធ្វើការជាមួយខ្ញុំនោះ តែឥឡូវអត់ដែលឃើញ តើលោកដឹងទេប្រជាជនគេនោះយកទៅណា?” យោធានោះក៏បាននិយាយប្រាប់ខ្ញុំច្បាស់លាស់ហើយថា៖ “ប្រជាជន១៧មេសានោះ គេយកចំនួនពីរបីឡានទ្រុងយកទៅវ៉ៃចោលនៅលើចំណោតសេអ៊ីអស់ហើយ។ បាទ រឿងនេះជារឿងពិតប្រាកដ។

[១០:៥១:៣៤]

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សី នៅពេលលោកធ្វើជាកងទ័ពជើងទឹក តើលោកមានដែលបានទទួលបញ្ជាឲ្យប្រព្រឹត្តខុសៗគ្នាដែរទេ បើសិនជាអ្នកចាប់បាននៅលើទូកជាជនជាតិថៃ ឬក៏ជាជនជាតិវៀតណាម? រវាងជនជាតិទាំងពីរនេះគឺបញ្ជាឲ្យលោកប្រព្រឹត្តខុសគ្នាដែរទេ? ធ្វើប្រព្រឹត្តទៅលើអ្នកទាំងហ្នឹងខុសៗគ្នា ឬក៏យ៉ាងណា?

**ឆ៖** បាទ មានការខុសៗគ្នាខ្លះ។ បាទ ខ្ញុំសូមជម្រាប កាលពីឆ្នាំ៧៦ បាទ មិនទាន់ចូលឆ្នាំ៧៧ខ្ញុំបានឆ្លើយនឹងសំណួរពីខាងមុនហួសបន្តិចហើយ ពេលនោះ ខ្ញុំផ្ទាល់បានចាប់ជនជាតិវៀតណាមៗមួយទូក ប្រហែលជាប្អូនដប់នាក់ប៉ុណ្ណោះទេ តែជនជាតិនោះមានអាវុធនៅលើកប៉ាល់នោះ លើទូកនោះឃើញថាបាញ់ត បាទ បាញ់តនឹងពួកខ្ញុំ។ បានបញ្ជាពីខាងលើ វាបាញ់ត គឺឲ្យបាញ់ពន្លិចចោលតែម្តង។ ពេលនោះ ពួកខ្ញុំក៏បាញ់ពន្លិចចោល បាទ បាញ់ពន្លិចចោល។ ពេលដែលខាងក្រោយមកទៀត ខ្ញុំចាប់បាននូវកប៉ាល់ថៃចំនួនបីគ្រឿងទៀត ម៉ាក៨០០សេសមួយគ្រឿង, ១៥០០សេសមួយគ្រឿង និង១២០០សេសមួយគ្រឿង, ជនជាតិថៃទាំងអស់នោះនៅលើទូក ក្នុងទូកនីមួយៗមានចំនួន២០នាក់, ១០នាក់, ១៥នាក់។ បាទ ជនជាតិថៃនោះគឺថា បញ្ជូនទៅរាមតែម្តង បាទ ទៅរាម។ ក្រោយមក ខ្ញុំបានទៅធ្វើការនៅរាម ជួបជនជាតិថៃនោះ ធ្វើការនៅទំនប់នៅរាម – នៅរាមទេ -- នៅកោះតាគាវៗ។ ខ្ញុំគេឲ្យធ្វើការនៅកោះតាគាវនោះ ក៏ខ្ញុំបានជួបជនជាតិថៃទាំងអស់នោះ។ ខ្ញុំសួរអ្នកយាមថៃនោះថា ជនជាតិថៃទាំងអស់នេះ គេ

សម្លាប់គាត់ចោល ឬមួយក៏គេយកទៅណាដែរហ្ន៎អ្នកយាម? អ្នកយាមនោះក៏បាននិយាយប្រាប់ខ្ញុំថា គេមិនសម្លាប់ចោលទេថៃទាំងអស់នេះ គេអាចបញ្ជូនគេទៅប្រទេសគេវិញ។ បាទ ខ្ញុំបានដឹងតែប៉ុណ្ណឹង។ បាទ អរគុណ។

[១០:៥៤:៣៩]

**ស៖** ចុះប្រជាជនវៀតណាមដែលមិនកាន់អាវុធ ដែលជាជនជាតិភៀសខ្លួននោះ រត់ដោយសារតែភៀសខ្លួន តាមដែលបទពិសោធន៍របស់លោក ជោគវាសនារបស់ប្រជាជនវៀតណាមទាំងនោះវាយ៉ាងណាដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសុំជំទាស់ទៅនឹងសំណួរនេះ ដោយសារបានសួររួចមកហើយ។ សហព្រះរាជអាជ្ញាសួរពាក់ព័ន្ធទៅនឹងថា តើប្រជាជនហ្នឹងជាកងទ័ពពាក់ឯកសណ្ឋានកាន់អាវុធ ឬក៏អត់។ ការដែលជាកងទ័ព មិនចាំបាច់ដល់ទៅកាន់អាវុធទេ។ បើសិនជាទូកណាមួយដែលមិនស្គាល់ ហើយចូលមកក្នុងដែនទឹករបស់ប្រទេសមួយ គឺថាមកដល់សព្វថ្ងៃក៏ដូចគ្នាដែរ ប្រទេសណាក៏ដូចប្រទេសណា គេតែងតែបញ្ឈប់ទូកនោះ មិនចាំបាច់ថាអ្នកនៅលើទូកនោះដល់ទៅពាក់ឯកសណ្ឋានកងទ័ព ឬក៏កាន់អាវុធទេ គេត្រូវតែបញ្ឈប់អ៊ីចឹងឯង។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់អំពីរឿងក្តីរបស់យើង គឺមិនស្លៀកពាក់ឯកសណ្ឋាន មិនកាន់អាវុធ។ អ៊ីចឹងខ្ញុំសួរញែកឲ្យដាច់ពីគ្នា។ ច្បាប់អន្តរជាតិមិនអនុញ្ញាតឲ្យសម្លាប់ជនស៊ីវិល ឬក៏កាន់អាវុធ។ បើទោះបីជាអ្នកទាំងនោះជាជន -- ជាអ្នកកាន់អាវុធក្តី កាលណាចាប់បានហើយ ក៏ច្បាប់អន្តរជាតិមិនឲ្យសម្លាប់គេដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺខ្ញុំចង់បញ្ជាក់ឲ្យៗលោកសួរញែកពីគ្នារវាង ថាតើមានពាក់ឯកសណ្ឋានកាន់អាវុធ ឬក៏អត់។ គឺសួរតែរឿងថាតើ ជនជាតិ -- តើសាក្សីរូបនេះបានឃើញអ្នកនៅលើទូកហ្នឹង ឬក៏អត់តែប៉ុណ្ណោះទៅបានហើយ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា មេធាវីការពារក្តី អាចមានពេលវេលាសួរនៅឆ្នាំក្រោយ ជាមួយនឹងសាក្សីរូបនេះ។

[១០:៥៦:៥៣]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី លោកនិយាយថា ជនជាតិថៃដែលគេចាប់បានហ្នឹង គឺមិនសម្លាប់ចោលទេ ប្រហែលជាគេបញ្ជូនទៅវិញ។ ខ្ញុំមិននិយាយថាអ្នកណាកាន់អាវុធ អ្នកណាស្លៀកពាក់ឯកសណ្ឋានទេ។ ខ្ញុំសួរតែថា លោកនេះ ទទួលបញ្ជាឲ្យធ្វើយ៉ាងម៉េចដែរ ទៅលើមនុស្សដែលលោកចាប់បាននោះ?

**លោក 2-TCW-1000៖**

**ឆ៖** បាទ ក្នុងនុ៎ង គឺជាជនជាតិវៀតណាមខុសប្លែកនឹងគ្នានឹងជនជាតិថៃ បាទ។ ជនជាតិវៀត-ណាម គឺសត្រូវស្លូវជាមួយរបស់ បាទ ប៉ុល ពត។ មិនអាច ទោះបីអ្នកឯងយោធា មិនយោធាក៏ដោយ ឲ្យតែមានអាវុធតបត គឺបាញ់ពន្លិចចោលតែម្តង។

**ស៖** ចុះនៅពេលដែលគេមិនមានអាវុធ ព្រោះលោកឆ្លើយថា ប្រជាជនភាគច្រើនដែលលោកបានបញ្ឈប់គេហ្នឹង គឺថាមិនមានអាវុធទេ ជាជនភៀសខ្លួនទេ។ លោកចាត់ការយ៉ាងម៉េច ជាមួយមនុស្សប្រភេទនេះ?

[១០:៥៨:១៣]

**ឆ៖** បាទ ខ្ញុំនិយាយពីមុនថា អ្នកដែលគ្មានអាវុធនោះ ឃើញថាចាប់បញ្ជូនទៅផែអូរឈើទាល ដើម្បីយកទៅកន្លែងមន្ទីរកងពល បាទ។ តែអាដែងខ្ញុំនិយាយថា ឆ្នាំ៧៦ ដែលខ្ញុំមិនទាន់ចូលនៅក្នុងកងវរសេនាធំ១៤០នេះ ពេលដែលខ្ញុំនៅក្នុងកងពល -- កងវរសេនាធំ៦២នោះ បាទ គឺថាពេលនោះដែលខ្ញុំនិយាយផុតហើយ តែខ្ញុំបានបញ្ជាក់ឡើងវិញថា ពេលដែលខ្ញុំចាប់កប៉ាល់ថៃ ហើយនិងកប៉ាល់យួន ដែលបានបាញ់ពន្លិចចោលនោះ អាហ្នឹងជាជាក់ស្តែងខ្លួនឯង ដោយបញ្ជា បញ្ជាជាវរសេនាតូច និងវរសេនាធំរបស់ខ្ញុំបាទ។ ពេលដែលកប៉ាល់ដែលរបស់យួន ដែលមួយគ្រឿងមានអាវុធ ដែលកប៉ាល់របស់យើងកម្ពុជាដែលកំពុងចលនាដេញ បាទ ដេញចាប់នោះ ហើយវាមានកាំភ្លើងដែលបាញ់ត បាទ បាញ់ត បាទ ក្នុងនុ៎ង គឺថា ដឹងតែជនជាតិវៀតណាមហើយ គឺថាមានអាវុធហើយ គឺថាទោះបីអ្នកឯងមិនយោធា ឬមួយមិនប្រជាជន និងប្រជាជនអីក៏ដោយ គឺថាឲ្យតែពិតប្រាកដជារបស់យួនហើយ មានអាវុធ បាទ អត់មានឲ្យនៅចាប់បានទេ គឺបាញ់ពន្លិចចោលតែម្តង។

**ស៖** ខ្ញុំសូមសួរលោកនៅក្នុងកិច្ចសម្ភាសន៍មួយទៀត ដែលលោកបានឆ្លើយជាមួយអ្នកស៊ើបអង្កេតម្នាក់ឈ្មោះ ដានី មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកនៅចាំទេ លោកបានឆ្លើយជាមួយអ្នក

ស៊ើបអង្កេតម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឈ្មោះ ដានី នៅឆ្នាំ២០០៧?

ឆះ បាទ នៅចាំដែរ ប៉ុន្តែឥឡូវភ្លេចមុខគាត់ហើយបាទ។ នៅចាំដែរ ពេលគាត់ទៅសួរក្នុងឆ្នាំនោះបាទ។

[១១:០០:៤១]

សះ ខ្ញុំនឹងអានផ្នែកមួយនៃកិច្ចសម្ភាសន៍លេខ ERN ជាភាសាខ្មែរ គឺឯកសារ E305/13.23/382, ERN ជាភាសាខ្មែរ 00955507 និងបន្តទៅទំព័របន្ទាប់, ជាភាសាបារាំង 00980444, អង់គ្លេស 00978576។ នៅពេលនោះ ដានី សួរថា -- លោកបានឆ្លើយថា-- "លោកបានចាប់យួនបានខ្លះមែនទេ? បើពួកគេចាប់យួនបាន គេសម្លាប់យួនទាំងអស់នោះចោលហើយ"។ "សួរ៖ តើគេសម្លាប់នៅឯណា? ឆ្លើយ៖ ពេលខ្លះគេយកមកសម្លាប់នៅលើកោះ។" ហើយ ដានី សួរបន្តទៅទៀត៖ "តើគេមិនបញ្ជូនអ្នកទាំងអស់នោះឡើងមកច្រាំងទេឬ? លោកឆ្លើយថា៖ ជួនកាលគេសម្លាប់នៅលើកោះ"។ ដានី សួរថា៖ "ភាគច្រើនគឺជាកងទ័ពយួន ឬក៏អត់? លោកឆ្លើយថា៖ ភាគច្រើនជាជនភៀសខ្លួនរត់ទៅប្រទេសទីបី។ ប្រជាជនភាគច្រើន គឺរត់គេចចេញពីសង្គ្រាមឆ្លងកាត់តំបន់យើង ពេលយើងចាប់បានពួកគេ គឺថាយើងបាញ់សម្លាប់ចោលទាំងអស់តែម្តង។ សួរ៖ តើនេះជាបញ្ជាកងពលឬ ដែលឲ្យចាប់ហើយសម្លាប់ចោលតែម្តង ឬក៏ការធ្វើដោយខ្លួនឯង? លោកឆ្លើយថា៖ ជាបញ្ជាមកពីកងពល។ ហើយសួរថា៖ អ្នកណាជាអ្នកបញ្ជាពីកងពល? លោកឆ្លើយថា៖ បញ្ជាចេញពី តាមុត។ តាមុត បញ្ជាឲ្យសម្លាប់ឬ? លោកឆ្លើយថា៖ បាទ តាមុត បញ្ជាឲ្យសម្លាប់។ ហើយសួរ៖ ថាតើមានបញ្ជូនមកលើច្រាំងខ្លះទេ? លោកឆ្លើយថា៖ មាន។

នៅត្រង់នេះ គឺយើងនិយាយ -- លោកឆ្លើយអំពីការសម្លាប់ជនភៀសខ្លួនដែលរត់គេចចេញទៅប្រទេសទី៣។ តើបញ្ជាឲ្យសម្លាប់ជនស៊ីវិលនេះ ជាបញ្ជាចេញមកពីខាងណាដែរលោក?

[១១:០៣:០៧]

ឆះ បាទ ពិតប្រាកដណាស់ ហើយសំណួរដែលលោកបានសួរនេះ ជារឿងនេះ រឿងពិតប្រាកដណាស់ ហើយអាដែងកប៉ាល់ កាណូតរបស់យួនភាគច្រើនដែលរត់ទៅប្រទេសទី៣នេះ ឃើញថា ជំនាន់នោះ ឃើញថាមានការច្របូកច្របល់ច្រើនណាស់ បាទ ច្របូកច្របល់ច្រើន។ អ៊ីចឹងបញ្ជាពីកងពល បញ្ជាកងពល មិនមែនបញ្ជាមកផ្ទាល់ខ្លួនឯង ខ្លួនខ្ញុំផ្ទាល់តែម្តងទេ គឺបញ្ជាមកវរសេនាធំ កងពលបញ្ជាមកវរសេនាធំ។ វរសេនាធំបញ្ជាទៅវរសេនាតូច វរសេនាតូចបានបញ្ជាអ្នកយោធា អ្នកដែលធ្វើសកម្មភាព។ ហើយជនជាតិវៀតណាម ដែលជាច្រើនលើកច្រើនសា ដែលគេខ្លះក៏គេបញ្ជូនមក ពេលច្រើនគេ

បញ្ជូនទៅដីគោក តែបើម្នាក់ពីរនាក់ ទៅបីនាក់ គឺអត់ទេ អត់បញ្ជូនទៅលើដីគោកទេ គេសម្លាប់នៅលើកោះក៏មាន អាហ្នឹង ខ្ញុំសូមជម្រាបដោយរឿងពិតប្រាកដ ដែលខ្លួនបានឃើញ ក្នុងខ្លួនខ្ញុំមិនទាន់ចេញមកនៅក្នុងកងពលវរសេនាធំ១៤០ទេ នោះគឺនៅក្នុងវរសេនាធំ៦២។ នេះជាសកម្មភាពនៅក្នុងវរសេនាធំ នៅ៦២២ របស់យើងខ្ញុំ។ អាហ្នឹងជាកងចាស់ ក្រោយមកបានខ្ញុំនិយាយឆ្នាំ៧៥ -- ៧៧នេះ អាហ្នឹងបានខ្ញុំរស់នៅផែអូរឈើទាល។ មុននោះ គឺថានៅខាងកោះ បាទ ខាងកោះពូលូវ៉ៃ។ ព្រឹត្តិការណ៍ហ្នឹងឃើញថា អស់លោកបានសួរខ្ញុំមែន ហើយខ្ញុំឆ្លើយទៅតាមសំណួរហ្នឹងពិតប្រាកដមែនបាទ។

[១១:០៥:០៦]

**ស៖** សូមអរគុណ។ នៅពេលដែលលោកនៅក្នុងវរសេនាធំ៦២ កោះពូលូវ៉ៃនោះ តើលោកចាំរឿងមួយទេ ដែលមានប្ដីប្រពន្ធវៀតណាម ហើយមានទារកមួយដែលមានអាយុប្រហែលមួយឆ្នាំ?

**ឆ៖** បាទ ខ្ញុំបាននៅចងចាំ។ ថ្ងៃមួយឃើញថា ចាប់បានវៀតណាមបីនាក់ ប្ដីនិងកូនម្នាក់ កូននោះតូច អាយុប្រហែលជាមួយឆ្នាំ។ ពេលនោះចាប់យកមកដល់កោះពូលូវ៉ៃ បាទ ដល់កោះពូលូវ៉ៃ។ ពេលនោះ ខ្ញុំឃើញយោធានៅកងពិសេសវរសេនាតូចរបស់វរសេនាធំ៦២២ យកប្រជាជននោះចងដាក់នៅក្រោមដើមដូង បាទ ក្រោមដើមដូង។ ក្រោយមកទៀតបានឃើញ បាទ បានគេសម្លាប់ៗចង ហើយឲ្យលុតជង្គង់វាយនឹងគល់ឬស្សី និងត្បូងចប ធ្វើឲ្យស្លាប់និងប្ដីទាំងប្រពន្ធ។ លុះមកក្រោយមកទៀត ខ្ញុំឃើញជាក់ស្ដែង ហើយឃើញកូនង៉ែតនោះ ប្រហែលជាអាយុមួយឆ្នាំតែប៉ុណ្ណោះ ពេលឃើញម្ដាយស្លាប់ហូរឈាមយ៉ាងខ្លាំង ក៏វាចូលមករកអោបម្ដាយ។ ក្រោយមកទៀត បានយោធាចាប់បោកនឹងគល់ដូងស្លាប់តែម្ដង។ បាទ នេះជារឿងពិតប្រាកដ។

**ស៖** តើក្នុងចំណោមអ្នកទាំងបីនាក់ហ្នឹង មានអ្នកណាម្នាក់ជាទាហានដែរឬទេ?

**ឆ៖** ក្នុងចំណោមទាំងបីនាក់ហ្នឹង គឺប្រជាជន បាទ ប្រជាជនទេ គ្មានសម្លៀកបំពាក់អី ក៏គ្មានយោធាដែរ ហើយជាប្រជាជនធម្មតា។

**ស៖** តើលោកដឹងទេ គេចាប់ពួកគាត់មកពីកន្លែងណា?

**ឆ៖** បាទ ក្នុងនុ៎ងឃើញថា ចាប់ឃ្លាតពីកោះពូលូវ៉ៃ ចំនួនប្រហែលចម្ងាយប្រហែលជា ៥គីឡូ បាទ ៥គីឡូពីកោះ ព្រោះកាណូតរបស់យួននោះតូច អ៊ីចឹងហើយវាមិនអាចបើកឆ្ងាយពីកោះនោះបានទេ ពីព្រោះរលកខ្លាំង។ អ៊ីចឹងបានគេចាប់បានតែម្ដង គឺប្រជាជនដែលសាមញ្ញធម្មតា។

**ស៖** សូមអរគុណ។ ឥឡូវនេះលោកនិយាយអំពីបញ្ជាមកពីថ្នាក់លើ មកពីកងពលចុះមកក្រោម

ថាតើបញ្ហាទាំងអស់ហ្នឹងគេបញ្ជូនតាមរបៀបអី? នៅពេលដែលលោកធ្វើការនៅកប៉ាល់ តើកាណូត ឬក៏កប៉ាល់នោះមានវិទ្យុទាក់ទងទទួលបញ្ហា ឬបញ្ជូនអ្វី ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ជាការពិតណាស់ ក្នុងកប៉ាល់នីមួយៗសុទ្ធតែមានវិទ្យុទាក់ទង បាទៗ។ បើយើងចាប់បាន គឺរាយការណ៍ជាបន្ទាន់ទៅវរសេនាតូច វរសេនាតូចរាយការណ៍ជាបន្ទាន់ទៅវរសេនាធំ វរសេនាធំរាយការណ៍ជាបន្ទាន់ទៅមន្ទីរកងពល។ បាទ ហើយបានបញ្ហាត្រឡប់មកវិញ បានអាចធ្វើបាន បាទបញ្ហាទៅឃោធាបាន បាទ។

**ស៖** តើធ្លាប់បានធ្វើរបាយការណ៍លាយលក្ខណ៍អក្សរដែរឬទេអំពីហេតុការណ៍ដែលកើតនៅលើសមុទ្រ មានធ្វើរបាយការណ៍ជាក្រដាសស្នាមលាយលក្ខណ៍អក្សរទេ?

**ឆ៖** បាទ ក្នុងនោះមានលាយលក្ខណ៍អក្សរដែរ បាទ ក្នុងឯកសារដែរ បាទ នៅក្នុងនោះ។

[១១:០៩:៤៦]

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំចង់បង្ហាញសាក្សីនូវរបាយការណ៍ឯកសារ។ យើងឃើញថា យើងមានឯកសារពីរច្បាប់ ហើយមានការបកប្រែខុសគ្នាបន្តិច គឺថាឯកសារ E3/928 ហើយនិង E3/929 ហើយជាឯកសារដែលដូចគ្នាបេះបិទ។ ហើយខ្ញុំចង់បង្ហាញទៅសាក្សីទាំងពីរ គឺថាឯកសារ E3/928។ សុំអនុញ្ញាតតុលាការដើម្បីបង្ហាញឯកសារជូនសាក្សី ហើយនិងបង្ហាញលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការបង្ហាញឯកសារនេះទៅសាក្សី។ ខ្ញុំដឹងថាអាចនឹងសំណើកែជំទាស់របស់ខ្ញុំត្រូវបដិសេធ ប៉ុន្តែ-- ខ្ញុំជំទាស់ការបង្ហាញឯកសារនេះ លោកប្រធាន គឺថាសាក្សីរូបនេះនៅថ្នាក់ក្រោមនៅក្នុងឋានានុក្រម ហើយគាត់មិនមានតួនាទីអីក្នុងការនិយាយពីរបាយការណ៍ ពីថ្នាក់លើមកក្រោម ហើយពីក្រោមទៅលើនោះបានទេ។ ប្រហែលសហព្រះរាជអាជ្ញាមានចេតនាចង់ឲ្យដាក់ភស្តុតាងដែលថាសាក្សីរូបភាពនេះនឹងបញ្ជាក់។ អ៊ីចឹង គឺថាគាត់មិនមែនជាអ្នកមិនសរសេររបាយ-ការណ៍ មិនមែនជាអ្នកទទួលរបាយកការណ៍ ហើយគាត់មិនដឹងថាតើរបាយការណ៍ចេញពីកងពលទៅលើ ឬទៅក្រោមនោះទេ។ អ្វីដែលគាត់តើអាចនិយាយបាននោះគឺថា អ្វីដែលចេញពីតួនាទីរបស់គាត់ទៅ

ត្រឹមលើ ហើយពីតួនាទីថ្នាក់លើរបស់គាត់មកគាត់តែប៉ុណ្ណឹងទេ អ្វីដែលគាត់ដឹងនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបំពេញបន្ថែមទៅនឹងការជំទាស់របស់លោក កូប៉េ។ មុនពេលសម្រេចថាតើអង្គជំនុំជម្រះយល់ស្របតាមសំណើររបស់សហព្រះរាជអាជ្ញា ឬអត់នោះ ខ្ញុំគិតថាយើងមានវិធីសាស្ត្រដែលត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃការសួរសំណួរ។ គឺថាមុនពេលផ្តល់ឯកសារទៅឱ្យសាក្សី ត្រូវតែសួរសំណួរជាមុនសិន ដើម្បីឱ្យដឹងថាតើសាក្សីហ្នឹងអាចដឹងព័ត៌មាននៅក្នុងឯកសារឬក៏អត់។ អ៊ីចឹងហើយទើបយើងប្រគល់ឯកសារជាក្រោយ។ ក៏ប៉ុន្តែឥឡូវនេះ សហព្រះរាជអាជ្ញាផ្តល់ឯកសារមុន ទៅសួរសំណួរតាមក្រោយបែបនេះ គឺវាធ្វើអ៊ីចឹងគឺថា វាលឿនពេក វាខុសពីការអនុវត្តពីមុន។

[១១:១២:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា សហព្រះរាជអាជ្ញានឹងបំភ្លឺចំណុចនេះ។ យើងដឹងថា របាយការណ៍នេះពាក់ព័ន្ធនឹងការចាប់ខ្លួន។ អ៊ីចឹងគេបានសួរការចាប់ខ្លួននេះពីមុនមកហើយចំពោះសាក្សីរូបនេះ។

**លោក នីកូឡាស គូមជែន៖**

បាទ ដោយជាក់លាក់គិតថាយើងយោង -- តើលោកចៅក្រមសួរខ្ញុំឬទេ? បាទ អ៊ីចឹងគឺជាក់លាក់គឺយោងទៅរកការចាប់ខ្លួន ហើយនិងការសម្លាប់នូវជនជាតិវៀតណាមដែលគេចាប់បាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានបញ្ហាទាក់ទងទៅនឹងវិធីសាស្ត្រ។ ក្រៅពីពាក្យចាប់ខ្លួនជាទូទៅនេះ ប្រសិនបើយើងចង់យោងទៅលើឯកសារដែលនិយាយអំពីហេតុការណ៍ជាក់លាក់ណាមួយ ត្រូវតែសួរសំណួរពាក់ព័ន្ធនឹងហេតុការណ៍ហ្នឹងសិនដើម្បីឱ្យដឹងថា តើសាក្សីមានព័ត៌មានបែបនេះ ដែរឬក៏អត់?

ហើយខ្ញុំឃើញថា នៅក្នុងឯកសារនេះនិយាយអំពីការទូរស័ព្ទជាសម្ងាត់។ ដូច្នេះ យើងត្រូវតែសួរសំណួរជាមុន មិនមែនដោយសារតែឯកសារហ្នឹងនិយាយអំពីការចាប់ខ្លួនជាទូទៅ វាអាចជាប់ពាក់ព័ន្ធនឹងសាក្សីទេ។ កាលពីមុននោះ គឺមេធាវីការពារក្តីគឺត្រូវបានគេអនុវត្តបែបនេះយ៉ាងតឹងរ៉ឹងចំពោះពួកយើង។ អ៊ីចឹងសូមធ្វើឱ្យតឹងរ៉ឹងចំពោះព្រះរាជអាជ្ញាផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតម្តងចុះ ហើយលើកក្រោយមិនធ្វើអ៊ីចឹងទេ លោកស្រីមេធាវីការពារក្តីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គួរតែទៅធ្វើស្របគ្នាឱ្យភាគីម្ខាងទៀតធ្វើឱ្យចប់ ហើយភាគីម្តងទៀតជាអ្នកធ្វើការជំទាស់ ហើយយើងនិយាយចុងក្រោយ បើសិនជាងើបហើយអង្គុយ អង្គុយហើយងើបរបៀបនេះ គឺគ្រាន់តែបញ្ហានេះយើងត្រូវចំណាយពេលអស់ច្រើនណាស់ ហើយវិធីក្នុងការអនុវត្តកន្លងមក យើងបានតឹងតែងលើបញ្ហានេះណាស់។ រហូតមកដល់ពេលនេះ គឺមានការអនុវត្តបែបនេះ គឺហាក់ដូចជាវាឈានចូលដល់អាណាធិបតេយ្យបន្តិចហើយ។

[១១:១៥:២៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា ឯកសារនេះត្រូវបានបង្ហាញជូនសាក្សីរួចមកហើយនៅពេលស៊ើបអង្កេត។ ដូច្នេះគាត់បានឆ្លើយតបទៅនឹងឯកសាររួចមកហើយ គាត់ស្គាល់ឯក-សាររួចទៅហើយ។ ខ្ញុំសូមយោងលើឯកសារ E319/23.3.43.3 ពេលនោះគេបានបង្ហាញឯកសារហ្នឹងជូនគាត់ ហើយវាមានភ្ជាប់ទៅនឹងកំណត់ហេតុរបស់គាត់។ ដូច្នេះគឺឯកសារហ្នឹងគឺគួរតែបង្ហាញរួចមកហើយកាលពីស៊ើបអង្កេតហ្នឹង។ អ៊ីចឹងសាក្សីគាត់ស្គាល់ឯកសារនេះហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៦:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវការជំទាស់របស់ក្រុមមេធាវីការពារក្តី អំពីការដាក់ ស្នើសុំដាក់បង្ហាញឯកសារចំនួនពីររបស់ក្រុមសហមេធាវី -- សហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ ដោយ-សារមូលហេតុឯកសារនេះក៏មានការពាក់ព័ន្ធ ហើយបញ្ហាព័ត៌មានដែលសាក្សីផ្តល់ហ្នឹងក៏មានការពាក់ព័ន្ធនឹងអង្គហេតុដែលយើងកំពុងតែពិភាក្សាដេញដោលនេះដែរ។ ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារ

អំមិញនេះដាក់ជូនសាក្សីពិនិត្យ ហើយនិងអនុញ្ញាតឲ្យខាងបុគ្គលិកពាក់ព័ន្ធនឹងខាងទូរទស្សន៍ដាក់បង្ហាញឯកសារហ្នឹងនៅលើអេក្រង់ទូរទស្សន៍។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដើម្បីសន្សំពេល ខ្ញុំនឹងសួរលោកអំពីវាក្យខណ្ឌទី១ ហើយនិងចំណងជើង ហើយនិងហត្ថលេខាតែប៉ុណ្ណោះទេ។ ខ្ញុំមិនសួរអំពីវាក្យខណ្ឌទី១ ទី២ នៅក្នុងរបាយការណ៍នេះទេ។

*(សាក្សីអានឯកសារ)*

លោកសាក្សី ខ្ញុំសួរសំណួរ ហើយលោកអាចនឹងមានពេលមើលឯកសារបាន។ ឯកសារហ្នឹងគឺមានកាលបរិច្ឆេទនៅលើខាងលើគឺថ្ងៃទី០១ មេសា ឆ្នាំ១៩៧៨។ ហើយនិយាយថា កងពល១៦៤ ផ្នែកនយោបាយនៅថ្ងៃទី០១ មេសា ឆ្នាំ១៩៧៨នោះ តើលោកស្ថិតនៅក្នុងកងពល១៦៤ហ្នឹងដែរឬទេ?

[១១:២០:២៧]

**លោក 2-TCW-1000៖**

**ឆ៖** បាទ ៧៨ ដល់ ៧៩ នេះខ្ញុំនៅ ស្ថិតនៅក្នុងកងពលដដែលៗ។

**ស៖** បាទ លោកស្ថិតនៅក្នុងកងពលហ្នឹងដែរឬទេ? ខ្ញុំមិនទាន់ទទួលចម្លើយ។ នៅថ្ងៃទី០១ មេសា ឆ្នាំ១៩៧៨ តើលោកស្ថិតនៅក្នុងកងពល១៦៤ ដែរឬទេ?

**ឆ៖** បាទ ក្នុងឆ្នាំ៧៤ នេះខ្ញុំគ្មានទេ។ ៧៩ បាទ ខ្ញុំនៅក្នុងក្របខ័ណ្ឌកងពលនេះដែរ។ បាទ ៧៩ -- ៧៨-៧៩បាទ។ តែដើមឆ្នាំ៧៩ បាទ នៅពេលវេលាតិចនៅក្នុងក្របខ័ណ្ឌកងពលនេះបាទ។

**ស៖** សូមអរគុណ។ អ៊ីចឹងយើងឃើញថា នៅខាងក្រោមចុះហត្ថលេខាក៏មានឈ្មោះដាក់ថា "មុត"។ តើនៅក្នុងកងពល១៦៤ អ្នកណាដែលមានឈ្មោះថា មុត? តើលោកស្គាល់ច្បាស់ទេ?

**ឆ៖** បាទ មុត គឺថា មាស មុត គាត់ប្រធានកងពលប្រចាំនៅកំពង់សោមតែម្តង។

**ស៖** វាក្យខណ្ឌទី១ គឺនិយាយអំពីឧបទ្ទវហេតុ ហើយខ្ញុំនឹងសួរពីរឿងនេះ តើលោកបានដឹងឬអត់? នៅទី១នេះនិយាយថា ហើយគឺមានការបកប្រែពីរខុសគ្នាជាភាសាអង់គ្លេស ខុសគ្នាបន្តិច ខ្ញុំការបកប្រែជាភាសាអង់គ្លេសគឺ E3/928 បាទ ចំនួនសរុបនៃមនុស្សដែលគេចាប់ខ្លួននោះ ដែលគេបាញ់សម្លាប់គឺជាជនជាតិវៀតណាមហ្នឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៣០ ខែ៣ ឆ្នាំដដែលនោះ គឺថាមានចំនួន១២៨ នៅក្នុងពេលនេះ ហើយលោកចាប់កាណូតម៉ាស៊ីនបីដែលមាន ១០០០សេសេ ហើយនិងគឺ៣០សេសេ ហើយនិងឧបករណ៍ដូចជា អាវុធផងដែរ។ តើសាក្សីមានដឹងពីរឿងហេតុការណ៍នេះទេ?

[១១:២៣:២៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់នៅក្នុងការរៀបសំណួរនេះ។ សហព្រះរាជអាជ្ញាប្រើឯកសារពីរ ហើយប្រយោគដែលគាត់មិនចូលចិត្ត គាត់ -- ហើយបើប្រយោគណាដែលគាត់ចូលចិត្ត គាត់យកឯកសារមួយមកប្រើ ឯកសារ E3/929 គឺ ហើយចំនួនសរុបគឺជនជាតិវៀតណាមដែលគេចាប់ ហើយមួយទៀត គឺឯកសារមួយទៀត គេចាប់បានហើយបាញ់សម្លាប់។ អ៊ីចឹងគាត់ៗប្រើឯកសារពីរយកចំណុចណាដែលគាត់ចង់បាន ប៉ុន្តែគាត់គួរតែប្រើឯកសារមួយយកសម្រង់ទាំងស្រុងបាទ។

[១១:២៤:២២]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំអាចនឹងនិយាយភាសាខ្មែរ បើខ្ញុំអាច ប៉ុន្តែខ្ញុំមិនអាច។ អ៊ីចឹងមេធាវី ទី១គឺថាក្រុមមេធាវីរបស់គាត់ហ្នឹងមានជនជាតិ -- សហសេវិកជាខ្មែរ ប៉ុន្តែខ្ញុំ សហសេវិកប្រាប់ខ្ញុំថានេះជាខ្លឹម-សារត្រឹមត្រូវដែលខ្ញុំប្រើ។ អ៊ីចឹងគឺបើសិនជាលោកប្រាកដថាណាមួយត្រឹមត្រូវ គឺថាលោកអាចប្រាប់ខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ តាមពិតហើយ គឺសហសេវិកជាតិរបស់លោក គូមជែន អាចនឹងអានជាភាសាខ្មែរ ហើយអ្នកបកប្រែអាចនឹងបកប្រែទៅជាអង់គ្លេសតាមហ្នឹង។

**លោក នីកូឡាស គូមជែន៖**

គឺអរគុណហើយដែលលោកបានផ្តល់មតិនេះ។ អ៊ីចឹងគឺថា សូមធ្វើតាមនេះលោកប្រធាន។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ លោកសាក្សីខ្ញុំនឹងអានឯកសារមួយដែលសហការីអន្តរជាតិរបស់ខ្ញុំបានអានឲ្យលោកអម្បាញ់មិញនេះ។ គឺឯកសារ E3/929 ហើយសូមបញ្ជាក់សម្រាប់កំណត់ត្រា

ប្រតិចារឹកដែរថា ឯកសារ E3/929 ហើយនិងឯកសារ E3/928 បន្ទាប់ពីការវិភាគនិងសង្កេត យើងខ្ញុំពិនិត្យឃើញថា ជាឯកសារតែមួយ។ ហេតុដូច្នេះ ខ្ញុំនឹងចាប់ផ្ដើមអាននៅលើឯកសារនេះដែលមានខ្លឹមសារទាំងស្រុង៖

“ចំណុចទី១ សរុបយួនដែលចាប់បាននឹងបាញ់ងាប់ចាប់ពីថ្ងៃ២៧ ខែ៣ ៧៨ មកដល់ថ្ងៃ៣០ ខែ៣-៧៨ មានចំនួន១២០ក្បាល ទូក១០សេះ ដល់ ៣៧សេះ ចំនួន៥គ្រឿង អាវុធមួយចំនួនក្នុងនោះ M79 មួយដើម និងសម្ភារៈផ្សេងមួយចំនួន”។ សូមបញ្ចប់ការដកស្រង់លោកប្រធាន។ សូមអរគុណ។

[១១:២៦:៤៦]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅពេលដែលលោកបានស្ដាប់ តើហេតុការណ៍ហ្នឹង តើលោកនៅចងចាំអំពីហេតុការណ៍នេះដែរឬទេ? បើលោកចាំ ថាចាំ, បើអត់ចាំ លោកឆ្លើយថាអត់ចាំបាទ។

**លោក 2-TCW-1000៖**

**ឆ៖** បាទ រឿងនេះខ្ញុំ -- រឿងរ៉ាវដែលក្នុងឯកសារនេះ ខ្ញុំអត់បានចាំទេ។ បាទ សូមអរគុណ។ ខ្ញុំអត់ចាំ។

**ស៖** បាទ សូមអរគុណ។ លោកសាក្សីនៅពេលមួយតាមបទសម្ភាសន៍ដែលខ្ញុំយល់នោះ លោកបាន គឺក្រោយឆ្នាំ១៩៧៩ ក្រោយពីរបបខ្មែរក្រហមរលំទៅ លោកបានធ្វើជានីរសារ។ តើរឿងនេះត្រឹមត្រូវទេ?

**ឆ៖** កាលពីឆ្នាំ៧៩ ខ្ញុំបានធ្វើជានីរសារនិងកងការពាររបស់ តាមុត។ នាំប្រជាជនដែលចេញពីក្រុងកំពង់សោមទៅប្រទេសថៃ ចំនួនប្រជាជនដែលខ្ញុំនាំទៅនោះឃើញថាមានចំនួន ៣០.០០០នាក់ បាទទៅប្រទេសតែម្ដង។ ដោយក្រោមការដឹកនាំរបស់ មាស មុត ដែលគាត់បញ្ជាឲ្យយើងខ្ញុំនាំប្រជាជនឆ្លងដែនទៅតែម្ដង។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីលើកក្រោយចាំស្ដាប់សំណួរសិន។ សំណួរមានសួរបន្តបន្ទាប់ ហើយសួរអំពីបញ្ហាអីឆ្លើយកម្រិតបញ្ហាហ្នឹងបានហើយ។ គេសួរថា តើលោកធ្លាប់ធ្វើៗនីរសារមែនទេ? គឺថាធ្វើនីរសារ ឬក៏មិនបានធ្វើ ហើយ។ ហើយចំពោះសំណួរដទៃទៀតគេនឹង ភាគីពាក់ព័ន្ធនឹងតាំងសំណួរលោកជាបន្តបន្ទាប់ទៀតហើយ។ កុំបារម្ភរឿងសំណួរ យើងបារម្ភខ្លាចតែលោកមិនមានលទ្ធភាពឆ្លើយតបនឹងសំណួរដែលមាន

រាប់រយ រាប់ពាន់ ក្នុងរយៈពេលដែលអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់លោកទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ លោកសាក្សី តើលោកអាចប្រាប់ខ្ញុំបានទេ ផ្អែកលើបទពិសោធន៍ដែលលោកបានជួបប្រទះ តើសារទាំងអស់នេះវាជាការទាក់ទងធម្មតារវាងកងពល១៦៤ ហើយនិយាយថា "ជូន អ៊ំនួន, បងរ៉ាន់ ហើយនិងឯកសារកាលប្បវត្តិ"។ តើជាការឆ្លើយឆ្លងរវាង មាស មុត ហើយនិងមនុស្សទាំងអស់នេះ គេដាក់ក្បាលជាសរសេរបែបអ៊ីចឹងជាធម្មតាឬទេ?

[១១:៣០:០៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន នេះច្បាស់ណាស់គឺការអញ្ជើញឲ្យសាក្សីនិយាយស្មាន។ គាត់មិនដឹងពី យល់ដឹងអំពីទំនាក់ទំនងរវាងកងពលទៅថ្នាក់លើទេ។ ការព្យាយាមជួយឲ្យគាត់ក្រោយពីឆ្នាំ១៩៧៩ បញ្ជាក់ពីតួនាទីរបស់គាត់នេះដើម្បីភ្ជាប់ទៅ១៩៧៨នោះគឺថា អាចនឹងគឺការព្យាយាមយកភស្តុតាងពីសាក្សីនេះ ឲ្យសាក្សីនេះនិយាយស្មានដើម្បីជាប្រយោជន៍របស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះទេ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសួរសាក្សីថា ដែលគាត់ដឹង ឬមិនដឹង ប៉ុន្តែបើគាត់ដឹង ឬមិនដឹង ហ្នឹងជាបញ្ហាដែលខ្ញុំសួរបន្ត ហើយក៏ខ្ញុំមិនដឹងថាចម្លើយរបស់គាត់យ៉ាងម៉េចដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សី តបទៅនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិនេះ។ សាក្សីស្តាប់យល់ ចូរឆ្លើយតបទៅនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសួរលោកអម្បាញ់មិញនេះ។

**លោក 2-TCW-1000៖**

**ឆ៖** បាទ រឿងរ៉ាវអស់ទាំងនេះឃើញថា ខ្ញុំអត់បានដឹងអីទាំងអស់បាទ។

[១១:៣១:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ហើយចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីកិច្ចដំណើរការ

សវនាការ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីពាក់ព័ន្ធផ្សេងទៀតផងដែរថានៅរសៀលនេះ នៅវេលាម៉ោងមួយ អង្គជំនុំជម្រះនឹងធ្វើនីតិវិធីសម្បថចំពោះអ្នកស៊ើបអង្កេតថ្មីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលនឹងចាប់ផ្ដើមពីម៉ោងមួយ។ ដូច្នេះ ភាគីសូមពន្យារពេលបន្តិចមុននឹងចូលមកកាន់កន្លែងអាសនៈរៀងៗខ្លួននៅក្នុងសាលសវនាការនេះ។ ទំនងជាអាចធ្វើតែ១៥ ឬក៏២០នាទីប៉ុណ្ណោះ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់កន្លែងបន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ នៅវេលាម៉ោងមួយកន្លះ ឲ្យបានមុនម៉ោងមួយកន្លះបន្តិចបានហើយ ព្រោះរសៀលនេះ អង្គជំនុំជម្រះជាប់ធ្វើបំពេញកិច្ចមួយចំនួនដែលអង្គជំនុំជម្រះបានជម្រាបជូនអម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចទៀត។ ព្រឹកមិញលោកបានជម្រាបតុលាការថា ជនជាវៀតណាមត្រូវបានគេចាត់ទុកថាជាសត្រូវស្សព្វជ។ តើលោកបានឮពាក្យនេះមកពីណាដែរ ពីកន្លែងណាដែរ?

**លោក 2-TCW-1000៖**

**ឆ៖** បាទ ជាការពិតណាស់ ខ្ញុំជាយុទ្ធជននៅកងពល១៦៤ ក្រោយពីបានឆ្នាំ១៩៧៦ បាទ គឺបើកជាវគ្គសាលាសិក្សា ដើម្បីប្រកាស បាទប្រកាសពេញសិទ្ធិ សត្រូវស្លូពូជ គឺវា យួននិងកម្ពុជា បាទ នៅក្នុងពេលនោះ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអរគុណ ប្រសិនបើលោកអាចនិយាយឲ្យបានលម្អិតបន្តិចអំពីវគ្គហ្វឹកហ្វឺននោះ។ តើវគ្គហ្វឹកហ្វឺននោះគេធ្វើឡើងនៅកន្លែងណាដែរ?

**ឆ៖** កាលនោះ ជាវគ្គសិក្សាដែលទៅតាមអង្គភាព ជាវរសេនាតូច។ ដោយវរសេនាតូចនោះ និងវរសេនាធំបានសិក្សាពីវគ្គមន្ទីរកងពលហើយ ក្រោយមកឃើញថា វគ្គសិក្សាទៅតាមសាលាតូចៗ នៅតាមជួរយោធាខាងមុខនៅលើកោះ គឺថាមានវគ្គសិក្សានៅតាមវរសេនាតូចៗនីមួយៗ ទូទាំងអស់នៅក្នុងកងពល។

[១៣:៣៤:១៧]

**ស៖** តើអ្នកណាខ្លះអ្នកចូលរួមនៅក្នុងវគ្គសិក្សានោះ។ តើគ្រូបង្វឹក គ្រូបង្រៀននៅកាលនោះមានអ្នកណាខ្លះ តើលោកចាំទេ?

**ឆ៖** បាទ អត់មាន ក្រៅពីគណៈបញ្ជាការរបស់ខ្លួន ទាំងសិទ្ធិជាវរសេនាតូច ប្រធាននៃវរសេនាតូចទេ ទទួលផែនការពីលើទៅ ពីមន្ទីរកងពលទៅ។

**ស៖** តើយោធាទាំងអស់ ហើយនិងកងនារីកទាំងអស់នៅក្នុងវរសេនាតូច ត្រូវបានតម្រូវឲ្យគេចូលរួមវគ្គសិក្សាហ្នឹងទាំងអស់ដែរឬទេ តាមអ្វីដែលលោកចាំនោះ?

**ឆ៖** បានជាគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺថាប្រកាសទូទៅ ទូទាំងអស់នៅក្នុងកងពល១៦៤តែម្តង។

**ស៖** លោកសាក្សី នៅពេលដែលលោកចូលវគ្គសិក្សាបែបនេះ តើលោកទាំងអស់គ្នា ហើយនិងយោធាផ្សេងៗទៀត យល់ថាវាមានសារៈសំខាន់ដូចម្តេចទេ? តើលោកជជែកវែកញែក ឬក៏លោកអាចតទល់អ្វីអំពីមុខវិជ្ជាដែលគេបង្រៀនបានដែរឬទេ?

**ឆ៖** បាទ នៅក្នុងពេលនុំងឃើញថា ដោយបានសិក្សានូវសត្រូវស្លូពូជរបស់គេបង្ហាត់បង្រៀននូវភាសានេះ ហើយក៏យោធាទាំងអស់ក៏គ្មានអ្នកណាមួយមានពាក្យអ្វីចេញដែរ ហើយអនុវត្តទៅតាមគោលការណ៍របស់កងពល និងអង្គភាពនីមួយៗទូទៅ។

**ស៖** សូមអរគុណដែលលោកបានជួយឆ្លើយបំភ្លឺ។ តើដោយពិតប្រាកដ តើគ្រូបង្ហាត់នោះនិយាយដូចម្ដេចនៅពេលដែលគាត់បង្រៀនអំពីសត្រូវស្លូតបូតវៀតណាមហ្នឹង? តើគាត់និយាយអំពីអ្វីខ្លះជាខ្លឹមសារ?

**ឆ៖** បាទ ជាការពិតណាស់ សត្រូវស្លូតបូតហ្នឹងគឺថា សម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយក៏អត់ឲ្យមានដែរ ព្រោះនេះជាសត្រូវស្លូតបូត គឺសម្លាប់ចោលតែម្ដង ព្រោះទំនាស់បដិបក្ខ។ បាទ នេះជាអង្គសិក្ខាសាលានៅក្នុងមន្ទីរនៃវរសេនាតូចនីមួយៗទទួលផែនការច្បាស់លាស់តែម្ដង។ បាទអរគុណ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរអ្វីទៀតទៅសាក្សីនេះទេ នៅពេលនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

[១៣:៣៧:៤៥]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរលោកស្រីនៅរសៀលនេះ -- សួរលោកនៅរសៀលនេះ។ ជាពិសេសគឺខ្ញុំសួរបញ្ជាក់ពាក់ព័ន្ធទៅនឹងចម្លើយដែលលោកបានឆ្លើយរួមមកហើយកាលពីព្រឹកមិញនេះ។ កាលពីព្រឹកមិញលោកឆ្លើយថា លោកបានចូលរួមនៅក្នុងវគ្គរៀនសូត្របច្ចេកទេសពីរ គឺខាងបច្ចេកទេសជើងទឹកមុនពេលដែលលោកទៅឈរជើងនៅកោះ ហើយនិងចូលទៅក្នុងកងពល១៦៤។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ កាលពីព្រឹកមិញលោកមានឆ្លើយអ៊ីចឹងមែនទេ?

**លោក 2-TCW-1000៖**

**ឆ៖** បាទ ពេលខ្ញុំបានហ្វឹកហ្វឺននៅសាលាយោធាពេល មុនពេលចូលកងនាវិកនោះ ឃើញថាបានៗចូលរៀនសូត្រពិតប្រាកដមែន។

**សៈ** តើលោកបានរៀនសូត្រហ្នឹងនៅកន្លែងណាដែរ?

**ឆៈ** សាលារបស់ខ្ញុំដែលហ្វឹកហ្វឺនសាលាយោធា ដែលហ្វឹកហ្វឺននៅនាវិកនោះ គឺកន្លែងទី១ ដំណាក់ស្ដេច។ ក្រោយមកបានទៅធ្វើនៅកោះរ៉ុងការ -- កោះរ៉ុងម្ចាស់ កោះម្ចាស់ បាទ នៅកោះរ៉ុង ប៉ុន្ដែកោះម្ចាស់។ បាទ សាលាពីរហ្នឹងឃើញថា ខ្ញុំទៅសិក្សាចប់នៅក្នុងកោះរ៉ុង និងវិលត្រឡប់មកនៅអូរតែលសុខាវិញ។

**សៈ** ការហ្វឹកហ្វឺនទាំងពីរលើកហ្នឹង មានរយៈពេលប៉ុន្មានខែដែរ? លោកនៅចាំទេ?

**ឆៈ** បាទ អរគុណណាស់ ហើយខ្ញុំហ្វឹកហ្វឺនរយៈបីខែតែប៉ុណ្ណោះ។

[១៣:៤០:០៦]

**សៈ** អ្នកណាជាគ្រូហ្វឹកហ្វឺន លោកចាំទេ?

**ឆៈ** បាទ អរគុណណាស់ កាលគ្រូដែលហ្វឹកហ្វឺនរបស់ខ្ញុំគឺមានឈ្មោះ បងចំ។ បងចំ ហ្នឹងគឺគ្រូបង្ហាត់បង្រៀនហ្វឹកហ្វឺននៅបើកបរបច្ចេកទេសខាងនាវិក។ ហើយបងចំ ហ្នឹងគាត់រៀនពីចិន បាទ ពីចិនផ្ទាល់។ ចប់ពីចិនហ្នឹងមក បានគាត់ចុះមកបង្រៀនដល់យើងខ្ញុំគ្រប់គ្នានៅតាមនាវិក ជាសិក្ខាសាលា។

**សៈ** បងចំ ហ្នឹងជាខ្មែរ ហើយគាត់ទៅរៀននៅចិន ហើយចុះមានគ្រូហ្វឹកហ្វឺនជាជនជាតិចិនផ្ទាល់តែម្ដងទេ?

**ឆៈ** បាទ អរគុណណាស់ ហើយកាលខ្ញុំហ្វឹកហ្វឺននៅសាលាដំបូង នៅដំណាក់ស្ដេចនៅក្នុងផែអូរឈើទាលនោះ គឺចិនបានចូលរួមតែរយៈប្រមាណកន្លះខែតែប៉ុណ្ណោះទេ ក្រោយមកបាន ចំ នោះគេចប់សាលាទៅជាខ្មែរសុទ្ធរបស់ -- ខ្មែរយើងទេ ប៉ុន្ដែគាត់បានសិក្សាពីចិនៗ។ តែចិនគាត់អត់ចេះដែរ ក៏ប៉ុន្ដែមានចឹបកខ្មែរម្នាក់ដែលបកប្រែឲ្យ, ចំ ហ្នឹងជាគ្រូបង្រៀន ដែលមកបង្ហាត់បង្រៀនយើងខ្ញុំជាសិក្ខាកាមនៅកន្លែងនោះ។

**សៈ** សូមអរគុណ។ ខ្ញុំមានសំណួរពាក់ព័ន្ធទៅនឹងគ្រូចិននៅអូរឈើទាល។ ពេលគ្រូចិនមកដល់ លោកមានឃើញកម្មាភិបាលជាន់ខ្ពស់ ឬក៏មេដឹកនាំជាន់ខ្ពស់អមដំណើរគ្រូចិនទាំងអស់នោះមកបង្រៀនទេ?

**ឆៈ** បាទ កាលនោះអត់មានទេ អត់មានឃើញអីទេ ឃើញតែគ្រូចិនដែលជិះឡានមកតែម្ដង ហើយនិងចឹបកហ្នឹងមកតែម្ដងទេ អត់មានអមដំណើរអីមកទេ។

**សៈ** សូមអរគុណលោកសាក្សី។ លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាអន្តរជាតិថា លោក

បានចូលរៀននៅកងពល --អ៎! នៅវរសេនាតូច (សុំទោស) ហើយលោកទទួលបញ្ជាឲ្យសម្លាប់ជនជាតិវៀតណាមពីរនាក់។ តើលោកដឹងថាគ្រូបង្រៀនលោកហ្នឹង មុនពេលបង្រៀនលោកហ្នឹងមានបានចូលរួមវគ្គបណ្តុះបណ្តាលអីទេ?

**ឆ៖** បាទ មុនពេលនោះ គឺថាលោកគ្រូរបស់ខ្ញុំ ខ្ញុំអត់បានដឹងដែរទេបាទ ព្រោះខ្ញុំចេញពីកោះនោះ ទៅៗនៅកន្លែងអូរឈើទាលហ្នឹង ឃើញថា ត្រង់គ្រូហ្នឹងបានទៅរៀនខ្ញុំផ្ទាល់តែម្តង។

[១៣:៤៣:៥០]

**សៈ** ខ្ញុំសូមអានន្ទូវចម្លើយដែលលោកបានឆ្លើយជូនកាលពីមុន។ ខ្ញុំសូមយោងលើឯកសារ E319/23.3.44 សំណួរចម្លើយ៣៣ ក្នុងភាសាទាំងបី គឺលោក ពេលនោះគឺលោកបានឆ្លើយថា លោកទទួលបានការបណ្តុះបណ្តាលនៅក្នុងវគ្គអប់រំរៀនសូត្រ ហើយពេលនោះគេបង្រៀនថា "វៀតណាមជាខ្មាំងសត្រូវ"។ ពេលនោះគេសួរលោកថា "ហេតុអ្វីបានជាលោកដឹងអំពីរឿងទាំងអស់នេះ? លោកឆ្លើយថា៖ ពីព្រោះមេបញ្ជាការកងវរសេនាតូច និងវរសេនាធំទៅរៀនសូត្រជាមួយនឹងកងពល ហើយពេលគេត្រឡប់មកវិញ គេបានបង្រៀនយើងអំពីរឿងនេះនៅក្នុងវគ្គអប់រំរៀនសូត្រ។" តើលោកនឹកឃើញឡើងវិញទេ លោកដឹងទេថានៅសម័យនោះ អ្នកដែលមកបង្រៀនហ្នឹងគឺគាត់ទៅទទួលការអប់រំនៅថ្នាក់កងពល ហើយបានមកបង្រៀនបន្តដល់លោក?

**ឆ៖** បាទ អរគុណណាស់។ ឋានៈជាវរសេនាតូច និងវរសេនាធំដែលបានទៅហ្វឹកហ្វឺនត្រឹមឋានៈត្រឹមកងពលៗទេ ហើយបានចុះផ្សព្វផ្សាយដល់យោធាទាំងអស់ដែលនៅក្នុងកងនាវិកទាំងអស់នៅតាមវរសេនាតូច។

**សៈ** តើសេនាធិការកងពលមានទីតាំងនៅទីណាដែរ?

[១៣:៤៥:៥៧]

**ឆ៖** ជាមូលដ្ឋានរបស់គាត់ គឺនៅជិតរង្វង់មូលនៃរោងកុនផ្សារលើកំពង់សោម។ ជាទីកន្លែងរបស់គាត់នៅជិត ស្ថិតនៅជិតទីនោះ។

**សៈ** លោកធ្លាប់ឮមេរបស់លោកចូល -- ឡើងទៅភ្នំពេញដើម្បីចូលរួមក្នុងវគ្គរៀនសូត្រទេ?

**ឆ៖** បាទ ក្នុងពេលនោះខ្ញុំឋានៈជាយុទ្ធជនមួយរូបនៅក្នុងក្របខ័ណ្ឌនៃកងពល នៃវរសេនាតូច ៦២ រហូតដល់១៤០នេះ ឃើញថាកិច្ចការងារផ្ទៃក្នុងរបស់អ្នកធំៗ គឺថាមិនមានឲ្យដឹងទេ។ ដឹងតែទទួលផែនការអ្វីៗផ្សេងៗដែលដាក់ចុះមកតែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណ។ កាលពីព្រឹកមិញនេះ លោកបានឆ្លើយថាពេលលោកស្កាត់កាណូតនោះ គឺដោយសារតែចង់ដឹងថាអ្នកនៅក្នុងកាណូតហ្នឹងជាទាហាន ឬក៏ជាស៊ីវិល ហើយមានកាំភ្លើងឬក៏អត់? ហើយចំពោះជនជាតិវៀតណាមហ្នឹង គឺគេចាប់បាននៅក្នុងដែនទឹកខ្មែរពេលដែលលោកចុះល្បាត។ តើព្រឹកមិញនេះ លោកពិតបានជាឆ្លើយអ៊ីចឹងមែនទេ ជូនទៅសហព្រះរាជអាជ្ញានោះ?

**ឆ៖** បាទ ពិតមែន។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ជាងហ្នឹងបន្តិចបានទេថាលោកទទួលបានការណែនាំអ្វីខ្លះនៅពេលដែលលោកស្កាត់ចាប់កាណូត ឬនាវាណាមួយនៅក្នុងដែនទឹកកម្ពុជា ដែលលោកត្រូវយាមល្បាតនោះ? លោកដឹងយ៉ាងម៉េចបានថាអ្នកនៅលើនាវាហ្នឹងមានកាំភ្លើងឬក៏អត់? ហើយជនជាតិអី? លោកដឹងបានដោយរបៀបម៉េច? មានវិធីអ្វីខ្លះដែលលោកត្រូវអនុវត្តនៅពេលនុ៎ង?

[១៣:៤៨:២៨]

**ឆ៖** បាទ នៅពេលនុ៎ង ខ្ញុំនៅនាវិក។ នាវិកនោះ គឺមិនងាយចេញទេ។ អ៊ីចឹងមានតែក្នុងអង្គភាពរបស់ខ្ញុំ ជាកងល្បាតការពារ គឺថាកងល្បាតការពារនោះផ្សេង។ ហើយនាវិករបស់ខ្ញុំនេះគឺថា មិនងាយបានចេញទេ ទាល់តែបញ្ជាពីថ្នាក់លើអាហ្នឹងបានៗចេញ។ អ៊ីចឹងខាងអ្នកល្បាតដែលក្នុងអង្គភាពខ្ញុំឃើញថាមានផ្សេងៗពីគ្នា។ អ៊ីចឹងហើយខ្ញុំក៏អត់បានចុះផ្ទាល់ដោយខ្លួនដែរ មានតែយោធាដែលក្នុងអង្គភាពជាមួយនឹងខ្ញុំ។

**ស៖** សូមអរគុណ។ ខ្ញុំសូមអាននូវចម្លើយដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតកាលពីមុន ហើយនិងការបញ្ជាក់ខ្លះអំពីលោក គឺនៅក្នុងឯកសារដដែល E319/23.3.44 គឺចម្លើយលេខ២៥។ ខ្ញុំនឹងអានចម្លើយនេះនៅពាក់កណ្ដាល ពេលនោះលោកឆ្លើយថា៖ "ពេលយើងចាប់កប៉ាល់វៀតណាម ពេលខ្លះគេឲ្យយើងបាញ់ចោលនៅទីនោះតែម្ដង ហើយយកកប៉ាល់ទទេមកកោះ។ ជាទូទៅហ្នឹង កាលណាចាប់បានតិចជាង២០នាក់ គឺគេបញ្ជាសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជា២០នាក់ត្រូវបញ្ជូនទៅអូរឈើទាល។" លោកសាក្សី ដូច្នេះលោកអាចបញ្ជាក់បានទេថា គឺលោកបញ្ជាបែបហ្នឹងមែនទេនៅពេលនោះ ហើយពេលចាប់បាន គឺគេត្រូវតែរាប់ចំនួនមនុស្សឲ្យបានពិតប្រាកដដែលមាននៅលើទូកនោះ ឬក៏កប៉ាល់មួយៗហ្នឹងមែនទេ?

**ឆ៖** បាទ ជាការពិតណាស់ ពេលនុ៎ងឃើញថា យើងខ្ញុំបានត្រួតពិនិត្យទៅឃើញថា ជាការពិតពេលដែលចាប់បានកាណូតនីមួយៗបាទ។ ពេលនុ៎ងឃើញថា បញ្ជាៗឲ្យយកទៅលើគោក តែបើតិច

ត្រឹមត្រូវម្នាក់ពីរនាក់តែប៉ុណ្ណោះ គឺថាមិនបានទេ។ បើថាការអនុញ្ញាតថាមិនបាច់យកមកទេ គេមានការបាញ់សម្លាប់នៅលើផ្ទៃសមុទ្រហើយ ហើយយកតែកាណូតដើម្បីមកប្រើប្រាស់ក្នុងអង្គភាពរបស់គេ។

[១៣:៥១:២៩]

**ស៖** លោកយល់ទេថា ពេលនុ៎ង ហេតុអីបានជាគេបញ្ជាឲ្យធ្វើបែបហ្នឹងចំពោះកាណូតដែលមានមនុស្សតិច ហើយនិងមនុស្សច្រើននុ៎ង?

**ឆ៖** បាទ ស្តាប់អត់សូវឮផង ឮតិចៗ។

**ស៖** ខ្ញុំនឹងសួរលោកម្តងទៀត។ លោកស្តាប់ខ្ញុំឮទេលោកសាក្សី? ខ្ញុំបានអាននូវចម្លើយរបស់លោក ដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេត ពេលនុ៎ងលោកថា បើចាប់បានតិចជាង២០នាក់ គឺមានបញ្ជាឲ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង២០នាក់ ត្រូវបញ្ជូនពួកគេទៅអូរឈើទាល។ អ៊ីចឹងខ្ញុំចង់សួរលោកថា នៅសម័យនុ៎ងលោកដឹងទេថា ហេតុអីបានជាគេបែងចែករវាងទូកដែលមានមនុស្សតិច ហើយនិងទូកដែលមានមនុស្សច្រើនបែបនេះ គេមានពន្យល់ហេតុផលទេ?

**ឆ៖** ក្នុងពេលនុ៎ងឃើញថា ជាយល់របស់ខ្ញុំឃើញថា ពេលតិចគេឲ្យសម្លាប់នុ៎ង ឃើញថាដោយគេខ្ជិលយកមកសួរចម្លើយ បាទសួរម្លើយ។ ភាគច្រើនតែវៀតណាមរត់ទៅប្រទេសទី៣ អ៊ីចឹងទៅអ៊ីចឹងគេចាប់ដែលបានច្រើនអ៊ីចឹងយកទៅសួរចម្លើយ អំពីព្រឹត្តិការណ៍ដែលនៅក្នុងប្រទេសកម្ពុជាហើយនិងប្រទេសវៀតណាមហ្នឹង តើមានចម្លើយយ៉ាងម៉េច។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។

លោកប្រធានខ្ញុំអស់សំណួរហើយ។

[១៣:៥៣:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ មានសំណួរដល់សាក្សីរូបនេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកឲ្យបំភ្លឺអំពីរឿងរ៉ាវរបស់លោក។ កាលពីព្រឹកមិញនេះ ខ្ញុំស្តាប់ឮថា លោកថាលោកចូលធ្វើជាកងទ័ព គឺកងទ័ពបដិវត្តន៍នៅឆ្នាំ៧៣។ តើខ្ញុំស្តាប់ឮអ៊ីចឹងត្រឹមត្រូវទេ?

**លោក 2-TCW-1000៖**

**ឆ៖** បាទ ខ្ញុំ -- មិនត្រឹមត្រូវទេ ព្រោះខ្ញុំនិយាយព្រឹកមិញ ខ្ញុំថាខ្ញុំចូលធ្វើកងទ័ពបដិវត្តន៍នេះតាំងចាប់តាំងពី៧២ ថ្ងៃទី០២ ខែ៥ ឆ្នាំ១៩៧២បាទ។ បាទ មិនមែន ៧៣ ទេ ៧២។

**ស៖** អ៊ីចឹង គឺពេលហ្នឹងគឺជាទ័ពរបស់រណសិរ្សរួមរួបជាតិ ដែលយើងហៅថា “ហ្វុង” ហ្នឹង ឬក៏ជាកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយលោកជាបក្ខជនទេ?

**ឆ៖** បាទ ខ្ញុំមិនមែនជាបក្ខជនអី សម្ព័ន្ធយុវកកអីទេ ខ្ញុំជាយុទ្ធជនដ៏សាមញ្ញ។ បាទ សាមញ្ញជាទីបំផុត។ ចូលតាំងពីឆ្នាំ១៩៧២ រហូតដល់ឆ្នាំ៧៥នោះ ខ្ញុំក៏នៅតែយុទ្ធជនរហូតដែរ បាទ មិនមែនជាតួកម្មាភិបាលអីទេ។

[១៣:៥៦:០៧]

**ស៖** នៅឆ្នាំ១៩៧៥ លោកឈរជើងនៅឯណា? ហើយលោកបានចូលរួមប្រយុទ្ធនៅសមរភូមិណា?

**ឆ៖** បាទ ឆ្នាំ១៩៧៥ ជាថ្ងៃ១៧ មករា *(ស៊ីក)* ដែលជាថ្ងៃរំដោះហើយ បាទ ថ្ងៃរំដោះហើយបានខ្ញុំចេញពីកងទ័ពតំបន់ តំបន់គឺខេត្តកំពត ចេញទៅកងពល១៦៤ នៅឆ្នាំ៧៥ហ្នឹងតែម្តង។

**ស៖** នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ លោកចូលរួមក្នុងការវាយរំដោះភ្នំពេញ ឬក៏លោកនៅកំពត?

**ឆ៖** បាទ នៅកំពត បាទ មកវិញនៅកំពត។

**ស៖** ដូច្នេះ លោកនៅកំពតរួច លោកទៅកំពង់សោមមែនទេ? មានន័យថា ភ្លាមៗក្រោយពីថ្ងៃ១៧ មេសា ហ្នឹង គឺលោកទៅកំពង់សោមតែម្តង ឬក៏លោកនៅកំពតហ្នឹងសិន មិនទាន់ទៅទេ?

**ឆ៖** បាទ គ្រាន់តែរំដោះខេត្តកំពតភ្លាម គឺយើងខ្ញុំចេញទៅតែម្តង ដោយការចាត់តាំងក្នុងកងរបស់ខ្ញុំ គឺទៅ។ ទៅនោះ ខាងកំពង់សោមកំពុងតែទាហាននៅ កំពុងតែច្របូកច្របល់មិនទាន់ចុះមកអស់ពីក្រុងកំពង់សោមទេ។ ទើបតែខ្ញុំ ពួកខ្ញុំបានទៅដល់ បានរៀបចំឲ្យចេញទាំងអស់ ប្រជាជន១៧មេសា

ទាំងទាហាននៅក្នុងក្រុងកំពង់សោមតែម្ដង។

[១៣:៥៨:០៥]

**ស៖** ពេលនៅកំពត ពេលរំដោះក្រុងកំពត ហើយនិងពេលដែលលោកទៅដល់កំពង់សោមនោះ តើមានការណែនាំជាក់លាក់អ្វីពាក់ព័ន្ធទៅនឹងអតីតទាហានលន់ នល់ អតីតមន្ត្រីរដ្ឋនៃរបបលន់ នល់ ទេ? លោកមានចាំអ្វីខ្លះពាក់ព័ន្ធនឹងរឿងនេះ?

**ឆ៖** បាទ រឿងរ៉ាវទាំងអស់នេះ ដែលការណែនាំរបស់អគ្គមេបញ្ជាការនៃវរសេនាតូច ក៏ដូចជាអគ្គមេបញ្ជាការនៃវរសេនាធំ បញ្ជាឲ្យទាហាន និងប្រជាជន១៧មេសា ចេញឲ្យផុតពីទីក្រុង ដើម្បីងាយស្រួលនៃកងទ័ព នៃកងយោធារៀបចំនៅទីនោះ។

**ស៖** លោកដឹងទេថា ក្រោយមកមានការធ្វើបញ្ជីឈ្មោះ អ្នកណាជាទាហាន ជាមន្ត្រីរដ្ឋការក្នុងរបបលន់ នល់ទេ? ហើយពេលដែលលោកទៅដល់កំពង់សោមនោះ លោកមានបានចូលរួមចាប់ខ្លួនអតីតទាហាន និងមន្ត្រីរដ្ឋការលន់ នល់ ទេ?

**ឆ៖** បាទ អរគុណណាស់ ពេលដែលជម្លៀសចេញពីកន្លែងមូលដ្ឋានក្នុងក្រុងកំពង់សោមរួចរាល់ហើយ គឺថាជួរនៃកងទ័ពយោធាទាំងអស់ គ្មានអីទៅពាក់ព័ន្ធ ឬមួយអ្វីមួយទៅទំនាក់ទំនងជាមួយប្រជាជន ឬទាហានអីទាំងអស់ គឺថាអត់មានត្រូវការទាក់ទងទេ។ ស្រេចតែខាងលើ បាទខាងលើគេរៀបចំនៅតាមមូលដ្ឋានខាងក្រោម។

**ស៖** ដូច្នេះមានន័យថា លោកទទួលបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុង ហើយពេលដែលប្រជាជនចេញទៅអស់ហើយ លោកលែងមានភារកិច្ចអីទៀតហើយ គឺថ្នាក់លើ គឺអ្នកផ្សេងទៀតជាអ្នកចាត់ចែងលើជោគវាសនារបស់អ្នកដែលគេជម្លៀសចេញហ្នឹង មែនទេ?

**ឆ៖** បាទ ជាការពិតណាស់។

**ស៖** កាលពីព្រឹកមិញនេះលោកបានឆ្លើយថា នៅពេលណាមួយនោះគេដាក់ទណ្ឌកម្មលោក ព្រោះថាគេសង្ស័យលោក ហើយលោកបាននិយាយអំពីមិត្តមួយចំនួនរបស់លោកដែលត្រូវបានបញ្ជូនទៅមន្ទីរអប់រំកែប្រែនៅទឹកសាប ប្រហែលជាខ្ញុំអាចនិយាយឈ្មោះនេះមិនត្រូវ។ តើលោកអាចបញ្ជាក់បានទេថា គេបញ្ជូនមិត្តរបស់លោកហ្នឹងទៅទឹកសាបមែនទេ?

**ឆ៖** បាទ ជាការពិតណាស់ ដែលមិត្តភក្តិដែលជិតស្និទ្ធនៅធ្វើការជាមួយនឹងខ្ញុំដែលគេចាប់ខ្លួនទៅនៅទឹកសាប ទៅដាក់ទឹកសាប ហើយខ្ញុំក៏ត្រូវគេដកសេចក្ដីទុកចិត្តជាការងារដែលក្នុងអង្គភាពរបស់

ខ្លួន -- ក្នុងកងរបស់ខ្លួនជាមិនល្អមួយ។ បាទ ក៏គេដកចេញ តែខ្ញុំអត់បានទៅនៅទឹកសាបទេ ខ្ញុំគ្រាន់តែនៅធ្វើស្រែក្នុងចំណោតរាម។ តែយុទ្ធមិត្តយើងដែលមួយចំនួនហ្នឹងបានគេចាប់យកទៅដាក់នៅទឹកសាបតែម្ដង។

**ស៖** តើលោកដឹងទេថា អ្នកដែលគេឃុំនៅទឹកសាបហ្នឹងជាមនុស្សប្រភេទណា? សុទ្ធតែជាអ្នកយោធា ឬក៏មានប្រជាជន១៧មេសា? គឺខ្ញុំចង់សួរថាប្រភេទដែលមនុស្សដែលត្រូវបានគេឃុំនៅទីនោះជាអ្នកណា?

**ឆ៖** បាទ នៅក្នុងទឹកសាបនុ៎ងឃើញថា ដែលអ្នកដែលគេយកដាក់នោះសុទ្ធសឹងតែយោធា អត់មានប្រជាជន១៧មេសា ឬមួយទាហានដែលចាស់របស់លន់ នល់ នោះគ្មានទេ។ គឺថានេះជាក្នុងជួរយោធានៃកងពល១៦៤ តែម្ដង គឺថាយកទៅដាក់នៅកន្លែងនោះ អត់មានលាយឡំទេ។

[១៤:០៣:១៨]

**ស៖** កាលពីព្រឹកមិញនេះ លោកបាននិយាយថាមិត្តភក្តិរបស់លោកមួយចំនួនត្រូវបានចាប់ខ្លួននិងឃុំនៅទឹកសាប ដោយសារតែពួកគេបានសរសេរពាក្យមិនសមរម្យ។ លោកដឹងទេថា ហេតុអីបានជាអ្នកជាយោធាផ្សេងទៀតដែរត្រូវបានគេឃុំនៅទឹកសាបដែរនោះ?

**ឆ៖** បាទ ជាទូទៅឃើញថា យោធាទាំងអស់ដែលខ្ញុំធ្លាប់ស្គាល់ហើយធ្លាប់ដឹង យោធាដែលនៅក្នុងរង្វង់កងពល១៦៤ ឃើញថា ជាទូទៅឃើញថា បើអ្នកមានសកម្មភាពៗប្រឆាំងអ្វីមួយ គឺថាមិនថាវរសេនាធំ៦១, ៦២, ៦៣, ៦៤ អីទេគឺថាចាប់យកទៅដាក់នៅទឹកន្លែងនោះទាំងអស់។ បាទ នេះគឺការពិត។

**ស៖** ខ្ញុំសូមឲ្យលោកបំភ្លឺចំណុចនេះឲ្យបានច្បាស់។ លោកចាំទេ ពេលដែលលោកធ្វើជាយោធាលោកមានត្រូវបានគេឲ្យធ្វើប្រវត្តិរូបទេ? ហើយប្រសិនបើគេឲ្យធ្វើ តើត្រូវសរសេរអ្វីខ្លះនៅក្នុងប្រវត្តិរូបនោះ?

**ឆ៖** បាទ អរគុណណាស់។ ឆ្នាំ១៩៧៥ ជាថ្ងៃរំដោះ០៧ មករា*(ស៊ីក)* ហើយ។ ក្រោយពីចម្រាញ់កងទ័ពឲ្យល្អ ដោយធ្វើប្រវត្តិរូប ធ្វើជាប្រវត្តិរូប។ ប្រវត្តិរូបនោះ សង្ខេបនិងប្រវត្តិរូបលម្អិត។ ឧទាហរណ៍៖ បើខ្លួនខ្ញុំផ្ទាល់ ប្រវត្តិរូបជាប់និន្នាការនយោបាយ ឪពុកម្ដាយបងប្អូនសាច់សាលោហិតធ្វើជាទាហានចាស់ បាទ ក៏មិនបាននៅក្នុងរង្វង់កងយោធាទៀតដែរ គឺគេត្រូវតែដកចេញពីយោធាដែរ។ អ៊ីចឹងហើយ ជាទូទៅក្នុងកងទ័ពពល១៦៤ទូទៅ បាទ គ្រប់ទាំងអស់សុទ្ធសឹងតែធ្វើប្រវត្តិរូបលម្អិត បាទ លម្អិត។ បាទ សូមអរគុណ។

**ស៖** គេឲ្យលោកធ្វើប្រវត្តិរូបតែម្តង ឬក៏ច្រើនដង?

**ឆ៖** ក្នុងពេលនោះ មិនមែនធ្វើតែម្តងទេ បាទ ពីរបីបួន ទៅ ប្រាំដង បាទ ពីរបីបួនប្រាំដង ក្នុងមួយឆ្នាំមានប្រាំដង។ អ៊ីចឹងគេយកប្រវត្តិរូបនេះ លើកទី១ គេថាប្រវត្តិរូបល្អ អ៊ីចឹង យើងធ្វើទៀត។ ហើយបើយើងធ្វើទៀត បើប្រវត្តិរូបហ្នឹងមានជាប់និន្នាការអី ជាប់និន្នាការនយោបាយណាមួយ គេទុកទុកហើយឲ្យធ្វើប្រវត្តិរូបហ្នឹងទៀត លុះត្រាណាដែលប្រវត្តិរូបហ្នឹងចូលជាផ្លុងមួយ។ បើអត់មានៗតែរហូត បើមានៗតែរហូត ហ្នឹងបានជាផ្លូវការរបស់អង្គការ។

[១៤:០៧:១២]

**ស៖** អ្នកដែលមានប្រវត្តិរូបមិនល្អ ជាពិសេសអ្នកដែលមានជាប់និន្នាការរបបចាស់ អ្នកដែលមានបងប្អូនធ្វើការនៅក្នុងជួរកងទ័ព ឬក៏នៅក្នុងរដ្ឋបាលនៃរបបចាស់ហ្នឹង គឺថាគេដកចេញ។ ដកចេញហ្នឹងលោកចង់មានន័យថាយ៉ាងម៉េច? គេយកអ្នកទាំងអស់ហ្នឹងទៅណា? ហើយក្រោយមកមានរឿងអ្វីកើតឡើងទៀតចំពោះអ្នកទាំងអស់នេះ?

**ឆ៖** បាទ នៅក្នុងកងពល១៦៤ របស់យើងខ្ញុំហ្នឹង តាមការក្តាប់ មានកងចល័តមួយ កងចល័តមួយគេហៅថា "កងតាចាយ" បាទ កងតាចាយនោះ។ ពេលដែលកងទ័ពយោធាដែលមានជាប់និន្នាការនយោបាយដែលមិនល្អ ឧទាហរណ៍ថា ខ្ញុំមានឪពុកម្តាយ គេឆ្លើយថាមានឪពុកម្តាយ ឬសាច់បងប្អូន បងប្អូនហ្នឹងមានជាប់ដែលថាជា កា.ហ្សេ.បេរបស់យួន ឬមួយកា.ហ្សេ.បេ, សេ.អ៊ី.អា របស់អាមេរិកាំង បាទ គេលែងទុកចិត្តខ្ញុំហើយ គេដកខ្ញុំនេះឲ្យទៅកងចល័តហ្នឹង។ ដល់កងចល័តហ្នឹងជាកងមួយដែលសម្រាប់ធ្វើតែស្រែទេ បាទ ជាកងនេះកងចល័តធ្វើស្រែនៅផ្តុំបបុស្ស នៅជិតស្នាច់ដែង បាទ ខាងជើងស្នាច់ដែងបន្តិច ខាងជើងកងកេងណោះ បាទ។ កន្លែងនោះហើយជាកន្លែង ជាអ្នកជាប់និន្នាការជាប់នឹងនយោបាយអ្វីមួយ គឺថាគេដកយកទុកកន្លែងនោះដើម្បីឲ្យធ្វើស្រែ ដឹងតែធ្វើស្រែតែប៉ុណ្ណោះ។ អរគុណ។

**ស៖** ដូច្នេះ គឺមានទាហានមួយចំនួនត្រូវបានបញ្ជូនទៅទឹកសាប ដែលកន្លែងនោះជាកន្លែងអប់រំកែប្រែ ហើយក៏មានទាហានដែលជាអ្នកដែលមានប្រវត្តិរូបមិនល្អនោះ ត្រូវបានគេដកចេញបញ្ជូនទៅកងចល័តដើម្បីធ្វើស្រែ។ ដូច្នេះ ខ្ញុំចង់សួរលោកថា លោកផ្ទាល់នេះ គេចាប់ គេបញ្ជូនលោកទៅមន្ទីរអប់រំកែប្រែ ឬក៏ទៅកងចល័តធ្វើស្រែ?

**ឆ៖** បាទ នៅ ដូចឧទាហរណ៍ដែលខ្ញុំមិនបានចូលទៅកងចល័តនោះព្រោះអីថា មូលហេតុថាអីបានគេអត់យកខ្ញុំទៅដាក់នៅកន្លែងកងចល័តនោះ។ នោះខ្ញុំបានខិតខំកសាងខ្លួន បាទ ខំកសាងខ្លួនណាស់

ទោះបីមានបញ្ហាអីក៏មានការខាំមាត់សង្កត់ចិត្ត ហើយយកចិត្តទុកដាក់ប្រឹង បាទប្រឹងធ្វើការ។ ពេលនោះក៏អត់បានគេបញ្ជូនទៅកន្លែងនោះ ដោយសារអនុសេនាតូច និងអនុសេនាធំរបស់ខ្ញុំមានការទុកចិត្ត ដឹងថាខ្ញុំកសាងខ្លួនបានមកវិញ អត់បានទៅកងចល័តហ្នឹងទេ។ ហើយក៏កងចល័ត ហើយកងទ័ពទាំងអស់ដែលបញ្ជូនទៅកងចល័តនោះ ដោយមូលហេតុដែលគេអត់យកទៅទឹកសាប មិនមែនទេ អាហ្នឹងកម្រិតទោសវាខុសគ្នា បាទ កម្រិតទឹកសាប អាហ្នឹងទោសធ្ងន់។ ហើយខាងកងចល័តនេះ មិនមែនទោសធ្ងន់ទេ ទោសស្រាលៗ គ្រាន់តែជាប់និន្នាការនយោបាយ ហៅថា កម្ពែលចាស់ពីសម័យលន់ នល់ ឬមួយហៅថាបងប្អូនសាច់សាលោហិតអីជាប់និន្នាការ ដូចជាធ្វើការងារមានសកម្មភាព ខាងអីជាប់ ហៅថាខាងជាប់គិញ ហៅគិញ បាទ គេហៅគិញហ្នឹង ជាប់ជា សេ.អ៊ី.អា ជាប់ជាអីអ៊ីចឹង អាហ្នឹងគេយកទៅដាក់នេះ អាហ្នឹងទោសស្រាលមួយកម្រិតទេ ហើយបើថាទោសធ្ងន់ បាទ យកទៅដាក់នៅទឹកសាបតែម្តង។ បាទ អរគុណ។

[១៤:១១:៥៤]

**ស៖** លោកអាចបញ្ជាក់អំពីចំនួនទាហានដែលបញ្ជូនទៅទឹកសាបបានទេ ច្រើន ឬក៏តិច? ហើយនៅកងចល័តហ្នឹងក៏អ៊ីចឹងដែរ ច្រើន ឬក៏តិច? ហើយគេមានប្រាប់ទេថា អ្នកណាខ្លះដែលមានជាប់ខ្សែ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ នេះ?

**ឆ៖** បាទ អរគុណណាស់ ហើយខ្ញុំជម្រាបឲ្យច្បាស់លាស់ថា ជាកងចល័ត បាទកងចល័តហ្នឹង មិនមែនអីជាជាប់ ហ្សេ.បេ – កា.ហ្សេ.បេ អីទេ គ្រាន់តែជាប់ជានិន្នាការអី បងប្អូនអី យើងមិនមែនអ្នកជាប់ផ្ទាល់ទេ គ្រាន់តែសាច់ញាតិអីហ្នឹង។ ដូចខ្ញុំមានបងអ៊ីចឹងទៅ បងខ្ញុំធ្វើ អ៊ីចឹងទៅ ធ្វើជា សេ.អ៊ី.អា អ៊ីចឹងទៅ អ៊ីចឹងខ្ញុំហ្នឹងជាប់ហើយ បាទ ជាប់ហើយ គេដកសេចក្តីទុកចិត្តហ្នឹង គេយកទៅដាក់នៅហ្នឹង អាហ្នឹងកងចល័ត កងផលិត គេហៅថា កងផលិត។ កងតាចាយ តាចាយហ្នឹង គឺកងផលិតសម្រាប់ធ្វើស្រែ។ ហើយបើថាអ្នកជាប់ជានិន្នាការ ឬមួយថាទោសដែលទៅទឹកសាប អាហ្នឹងខុសគ្នា បាទ ខុសគ្នា មួយទោសធ្ងន់ មួយគ្រាន់តែទោសស្រាលប៉ុណ្ណោះទេ។ បាទ សូមអរគុណ។

**ស៖** លោកដឹងចំនួនអ្នកដែលធ្វើការនៅកងចល័តក្រោមការគ្រប់គ្រងរបស់តាចាយ ទេ? ហើយអ្នកទាំងអស់ហ្នឹង សុទ្ធតែជាអ្នកមានប្រវត្តិរូបអាក្រក់ មែនទេ?

**ឆ៖** បាទ ជាការពិតណាស់ នៅកងចល័តហ្នឹងសុទ្ធតែ ចំនួន មានចំនួនច្រើនដែរ ប្រហែលជាបួនទៅ ៥០០នាក់ដែរ អាហ្នឹងកងតាចាយ ហ្នឹង គឺកងផលិត។ រីឯនៅទឹកសាបនោះ ក៏បាន ខ្ញុំបានឃើញ

ផ្ទាល់ម្ដងជាពីរដងដែរ ប៉ុន្តែមិនច្រើនប៉ុន្មានទេ ប្រហែលជា៥០-៦០នាក់ តែប៉ុណ្ណោះនៅក្នុងទឹកសាបនោះ ដោយខ្ញុំដើរ ហើយក៏ខ្ញុំក្រឡេកឃើញនៅក្នុង អ្នកមានជាប់ទោសនៅខាងទឹកសាបហ្នឹង។ តែបើកង ចល័តវិញ ឃើញថាបានជួបគ្នាជាព្រឹកល្ងាច បាទ។

[១៤:១៤:៤៤]

**ស៖** កាលពីព្រឹកមិញនេះ ខ្ញុំយល់ថាលោកទទួលបានទណ្ឌកម្ម ដោយសារតែគេលែងជឿទុកចិត្តលោក ពីព្រោះថាក្រុមរបស់លោកហ្នឹងពាក់ព័ន្ធនឹងការសរសេរពាក្យមិនសមរម្យ។ ហើយមិត្តភក្តិរបស់លោកហ្នឹង ត្រូវបានគេបញ្ជូនទៅទឹកសាប។ ចុះលោក គេបញ្ជូនលោកទៅណាដែរពេលនោះ?

**ឆ៖** បាទ អរគុណណាស់។ ក្រោយពីបានកសាងខ្លួន ខ្ញុំបានប្រឹងប្រែងយកចិត្តទុកដាក់ បំពេញនូវភារកិច្ចរបស់គេ អ្វីក៏បានៗ អង្គការក៏បានទុកចិត្តខ្ញុំជាជនមួយល្អ បាទ បញ្ជូនខ្ញុំទៅនៅក្នុងកងរបស់ខ្លួនវិញ ក្នុងកងវរសេនាធំ១០០ -- ៦៦២ នោះវិញ។ បាទ អរគុណ។

**ស៖** ខ្ញុំយល់អំពីរឿងនេះ ក៏ប៉ុន្តែមុនពេលគេបញ្ចូលលោកទៅវិញនោះ គេបញ្ជូនលោកទៅណាសិន? ខ្ញុំដឹងថាគេមិនបញ្ជូនលោកទៅទឹកសាប ហើយក៏មិនបញ្ជូនទៅកងចល័ត។ អ៊ីចឹងពេលនុ៎ង គឺលោកទៅណា?

**ឆ៖** បាទ អរគុណណាស់។ គេបញ្ជូនខ្ញុំវិលត្រឡប់ទៅនៅកោះវិញ បាទ កោះអង្គភាពដើមរបស់ខ្លួនវិញ។

**ស៖** កាលពីព្រឹកមិញនេះ ខ្ញុំស្ដាប់ឮថា នៅពេលដែលគេបញ្ជូនទៅកោះដើមវិញ លោកឃើញអ្នក១៧មេសា។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំកាលនោះ ខ្ញុំបានរស់នៅជាមួយគ្នា បានធ្វើការជាមួយគ្នានឹងប្រជាជន១៧ មេសា នៅបបុស្ស ពុតទេ នៅភូមិគគីរនោះហើយ ដែលបាត់បង់អស់ហើយ ក៏យើងខ្ញុំនៅធ្វើការជាមួយអង្គភាព ដែលនៅអ្នកដឹកអ្នកធ្វើស្រែ បាទ អ្នកធ្វើស្រែនៅក្នុងកងរបស់ខ្លួន ដែលមិនល្អជាមួយគ្នានោះ ឃើញថាពេលនោះក៏គេយកចិត្តទុកដាក់ប្រឹងប្រែងកសាងខ្លួនរួចហ្នឹង ហើយក៏វិលត្រឡប់ទៅនៅក្នុងអង្គភាពចាស់វិញ។ រីឯជីវប្រវត្តិរបស់ប្រជាជន ១៧មេសា នេះឃើញថា ដូចខ្ញុំបានជម្រាបពីខាងដើមហើយព្រឹកមិញនោះ ក្រោយពីបានគេដឹកយកទៅសម្លាប់ចោលអស់ ខ្ញុំក៏ក្រោយមកបានវិលត្រឡប់ទៅក្នុងអង្គភាពវិញដែរ បានរួចខ្លួនពីទុក្ខទោសអស់ទាំងនោះ។

[១៤:១៨:០៣]

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្វីដែលលោកបាននិយាយពាក់ព័ន្ធទៅនឹងប្រជាជន១៧មេសា។ កាលពីព្រឹកមិញនេះ លោកបាននិយាយថា លោកឃើញថាអ្នក១៧មេសា មួយចំនួននុំងបាត់ខ្លួន។ ហើយលោកដឹងទេ ហេតុអីបានជាអ្នកទាំងអស់ហ្នឹងបាត់ខ្លួន?

**ឆ៖** បាទ កន្លងមក ដោយមូលហេតុខ្ញុំបាត់ខ្លួន ដោយរាល់ថ្ងៃធ្វើការរស់នៅធ្វើការជាមួយនឹងគ្នា បាទ ជាមួយខ្ញុំ ជាមួយជនដែលសមាសភាពមិនសូវល្អហ្នឹង ឃើញថាបានធ្វើជាមួយគ្នា។ ដល់តែក្រោយមកចេះតែបាត់ទៅៗហ្នឹង ខ្ញុំក៏បានស៊ើបសួរដែលកងនៅប្រចាំការនៅឃ្លាលទារក្បែរនុំង ក៏បានសួរទៅគាត់ថាប្រជាជន១៧មេសា ប្រហែលជាពីរបីឡានទោះគេយកទៅសម្លាប់អស់ហើយ។ បាទ ខ្ញុំក៏អស់មានការសង្ស័យ ពិតជាគេសម្លាប់មែនហើយ ក៏ខ្ញុំខំប្រឹងធ្វើការជាមួយបងប្អូនដែលជាប់និន្នាការជាមួយគ្នាប៉ុន្មាននាក់ហ្នឹងក៏ប្រឹងប្រែងធ្វើ កសាងខ្លួនបានហើយ ក៏បានជាល្អ ឃើញថាកម្មាភិបាលគេមានការទុកចិត្តទៅ បញ្ជូនខ្ញុំទៅកោះ ទៅអង្គភាពចាស់វិញនៅកោះនោះ បាទ នៅកោះ។ បាទ អរគុណ។

**ស៖** ដូច្នេះគេពិនិត្យមើលប្រវត្តិរូបរបស់យោធា។ អ៊ីចឹងលោកដឹងថាគេមានបានស្វែងរកប្រវត្តិ-រូបរបស់អ្នក១៧មេសាទេ? ហើយគេមានស្វែងរកមើលថា តើអ្នកណាខ្លះអាចជាទាហាន ឬក៏អ្នករដ្ឋការនៅសម័យលន់ នល់ ទេ?

**ឆ៖** បាទ នៅពេលនុំងឃើញថា ប្រវត្តិរូបតាមការត្រួតពិនិត្យរបស់ខ្ញុំ ក្នុងអង្គភាពនីមួយៗ ឃើញថា អត់មានទេ បាទ អត់មានថាប្រវត្តិរូបក្នុងជាប់និន្នាការ ខ្លះធ្វើទាហាន ឬមួយខ្លះក៏ជាប់និន្នាការអីទេ គឺប្រវត្តិរូបល្អណាស់ ស្អាតគ្មានជាប់និន្នាការនយោបាយអីទាំងអស់។ ពេលនោះ ឃើញថា បាននៅក្នុងអង្គភាពនីមួយៗបាន។ បើមាននិន្នាការអ្វីមួយ ឃើញថា អត់បានទេ គ្រាន់តែអ្នកជាប់គុកយួន គុកនៅប្រទេសកាលឆ្នាំ៧៥ហ្នឹង ក្នុងនោះឃើញថា ក៏គេអត់ឲ្យនៅដែរ ក្នុងអង្គភាពវិញដែរ។ ហ្នឹងគេដកចេញជាបន្ទាន់នៅពេលនោះ។ នេះខ្ញុំជម្រាបដូចខាងដើមអ៊ីចឹងហើយ។

[១៤:២១:១៤]

**ស៖** ខ្ញុំមិនសូវយល់ចម្លើយរបស់លោក ហើយលោកប្រហែលជាមិនយល់ទាំងស្រុងនូវចម្លើយរបស់ខ្ញុំ។ អ៊ីចឹងខ្ញុំសួរតាមរបៀបផ្សេងវិញ។ ខ្ញុំមិននិយាយអំពីទាហាន ឬក៏យោធាទេ ខ្ញុំនិយាយអំពីប្រជាជន១៧មេសា ដែលលោកបានធ្វើការជាមួយនោះ។ អ្នក១៧មេសាទាំងអស់នោះ គេមានស្រាវជ្រាវរកមើលប្រវត្តិរូបទេ? ហើយគេមានមើលថា តើក្នុងចំណោមអ្នក១៧មេសាទាំងអស់ហ្នឹង មានអ្នកណាខ្លះធ្លាប់ជាទាហាន ឬក៏មន្ត្រីរដ្ឋការនៅសម័យ លន់ នល់ ទេ?

**ឆ៖** បើតាមការដឹងរបស់ខ្ញុំ ឃើញថា ប្រជាជន១៧មេសា ជាទូទៅឃើញថា គ្មានគេទៅធ្វើប្រវត្តិរូបអីទេ បាទ អត់មានធ្វើអីទាំងអស់។ បាទ អរគុណណាស់ ខ្ញុំបាទជម្រាបត្រង់ប៉ុណ្ណឹង។

**ស៖** កាលពីព្រឹកមិញនេះ លោកដូចជានិយាយអំពីឈ្មោះ តាឌឿន ដែលជាអ្នកមានឋានៈធំទទួលខុសត្រូវនៅកំពង់សោម លោកចាំទេ តាឌឿន ហ្នឹងលោកបាននិយាយកាលពីព្រឹកមិញ?

**ឆ៖** បាទ ពីព្រឹកមិញ ខ្ញុំបាននិយាយពីតា -- មិនមែន តាឌឿន ទេ តា -- ភ្លេចឈ្មោះគាត់ទៀតហើយ។ តានោះគាត់ជាភូមិភាគបូព៌ាទេ បាទ តាឌឹម មិនមែន តាឌឿន ទេ តាឌឹម។ តាឌឹម គាត់នៅភូមិភាគបូព៌ា។ ពេលហ្នឹងគាត់មានកងទ័ពរបស់គាត់ដកពីភូមិភាគបូព៌ាទៅ ទៅនៅកំពង់សោមចំនួនមួយវរសេនាធំ។ មួយវរសេនាធំនោះ ហើយគាត់ជាគណៈមួយកងពល។ អ៊ីចឹង តាឌឹម នោះ គាត់បានទទួលរួមធ្វើការជាមួយនឹង តាមុត ដែរ គ្រាន់តែក្រោម តាមុត – នៅក្រោមការដឹកនាំរបស់ តាមុត។ ហ្នឹងខ្ញុំដឹងនៅពេលនោះ។

**ស៖** តើមានរឿងអ្វីកើតឡើងចំពោះ តាឌឹម ហើយនិងវរៈដែលមកពីខាងបូព៌ានោះ?

[១៤:២៤:១១]

**ឆ៖** បាទ នៅពេលនោះ តាឌឹម គាត់ជាប្រធាន បាទប្រធាន និងអនុតាមុត។ ក្រោយមក គាត់បានចាប់ខ្លួន បាទ បាត់ទៅ។ ពេលដែលចាប់ខ្លួនទៅ កងទ័ព កងយោធាទាំងអស់ជាកងយុទ្ធភូមិភាគបូព៌ានោះ ឃើញថា ឃើញចាប់ខ្លួនជាបន្តបន្ទាប់រហូតដល់អស់រលីងនៅកំពង់សោម កងភូមិភាគបូព៌ាអត់មាននៅសល់ទេ ក្រោយមកចាប់ទាំងអស់ ចាប់បាត់អស់។ ខ្ញុំក៏អត់ដែលឃើញអីទាំងអស់ មិនដឹងចាប់យកទៅណា ទៅណីទេ អត់ឃើញទេ។ បាទ សូមអរគុណ។

**ស៖** លោកចាំកាលបរិច្ឆេទនៃការចាប់ តាឌឹម ហើយនិងទាហានបូព៌ាហ្នឹងទេ?

**ឆ៖** នៅក្នុងរង្វង់នោះ ខ្ញុំបានចងចាំខ្លះ។ ក្រោយពីតាឌឹម គេចាប់ខ្លួនបាត់ហើយ ក្រោយមកចាប់យោធាៗដែលកងពលរបស់គាត់ជាវរៈ មួយវរសេនាធំនោះ។ ដោយសារដែលគេចាប់ តាឌឹម បាត់ទៅ គឺ តាឌឹម នោះគឺគាត់មានចម្លើយយ៉ាងម៉េចទេ ឬដឹងចម្លើយយ៉ាងម៉េចអីយ៉ាងម៉េចទេ ហើយសាច់ទ័ពរបស់គាត់ដែលរស់នៅក្នុងកំពង់សោមនោះ សុទ្ធតែជាប់និន្នាការនយោបាយចម្លើយពីរបស់ តាឌឹម ទាំងអស់ ក្រោយមកបានគេចាប់ដកចេញទាំងអស់ ប៉ុនមិនដឹងដកចេញទៅកន្លែងណាទេ។ មិនមែនបញ្ជូនទៅភូមិភាគបូព៌ាវិញទេ គឺមិនដឹងយកទៅត្រង់ណាទេ បាត់ទាំងអស់ បាត់អត់ដែលឃើញទេមួយវរសេនាធំហ្នឹង។

**សៈ** តើការចាប់ខ្លួនទាំងខ្សែរបែបនេះ មានតែម្តងទេ ឬក៏មានការចាប់ខ្លួនរបៀបនេះច្រើនដង? ដូចជាមានការចាប់អ្នកដែលមានឋានន្តរសក្តិខ្ពស់ៗតទៅទៀត ឬក៏យ៉ាងម៉េច?

[១៤:២៦:៤០]

**ឆៈ** បាទ កន្លងមកឃើញថា កាលនោះឃើញចាប់ជាកម្មាភិបាល អនុសេនាតូច កម្មាភិបាលក្រុម ចាប់ម្តងពីរដងៗ បីបួននាក់ៗៗអ៊ីចឹងទៅ ចេញពីក្នុងអង្គភាពនីមួយៗ ព្រោះអង្គភាពនុ៎ងក្រោយមកឃើញថាពេល តាឌឹម គេចាប់គាត់ទៅ ក្នុងអង្គភាពរបស់គាត់គេរំលាយ។ រំលាយកងវរសេនាធំនោះ បញ្ចូលទៅតាមវរសេនាធំគ្រប់វរសេនាធំ ទាំងវរសេនាធំ៦១ វរសេនាធំ៦២, ៦៣។ បាទ ក្នុងវរសេនាធំនីមួយៗគឺថាចម្រុះទាំងអស់។ ក្រោយមកឃើញថា ចាប់មកជាបន្តបន្ទាប់ មិនមែនចាប់តែម្តងទេ ឃើញថាចាប់ម្តងៗ បីបួននាក់ៗ ម្តងបួនដប់នាក់អ៊ីចឹងទៅបាទ។ អរគុណ។

**សៈ** អម្បាញ់មិញនេះលោកនិយាយអំពីចម្លើយសារភាព។ តើលោកធ្លាប់ទទួលបានការណែនាំ ឬក៏ធ្លាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលគេប្រាប់អំពីចម្លើយសារភាពរបស់អ្នកដែលត្រូវបានគេចាប់ខ្លួននោះ? លោកចាំទេថាមានរឿងអ៊ីចឹងទេ?

**ឆៈ** បាទ នៅពេលនោះ ខ្ញុំអត់បានដឹងដែរ ប៉ុន្តែតាមការស្តាប់ទៅឃើញថា ចម្លើយពីខាងលើមកវាជាប់កងទ័ពទាំងអស់នោះ យោធាទាំងអស់នុ៎ង ឃើញថា ជាប់និន្នាការនយោបាយរបស់គាត់ទាំងអស់ហើយ។ អ៊ីចឹងគេយកមេទៅហើយ អ៊ីចឹងគេសង្ស័យថា ទ័ពទាំងអស់ដែលវរសេនាធំដែលគាត់មកពីភូមិភាគបូព៌ានោះ ជា -- គេលែងទុកចិត្តហើយ គេដកចេញ មិនដឹងដកចេញទៅណាទេ អត់ដែលដឹង អត់ដែលឃើញ មិនដឹងចាប់យកទៅណា យកទៅណីទាំងអស់ អត់មានឃើញអីមួយទេ។ អរគុណ។

**សៈ** ពាក់ព័ន្ធនឹងចម្លើយសារភាពនេះដដែល លោកបានឆ្លើយថា ជនជាតិវៀតណាមមួយចំនួនដែលជាយោធា ហើយមានកាំភ្លើងត្រូវបាននាំមកដីគោក រួចមកបញ្ជូនតទៅទៀត។ ចុះលោកធ្លាប់ស្តាប់ឮអំពីចម្លើយសារភាពរបស់យោធាវៀតណាមទេ?

**ឆៈ** បាទ ខាងជើងទឹកនេះ ឃើញថាខ្ញុំអត់មានដែលបានទេ បានតែស្តាប់ខាងវៀតណាមខាងជើងគោកវិញទេ។ តែខាងជើងទឹកនេះ ដែលចាប់បានហើយ អត់ដែលឮសួរសំឡេងចម្លើយអីទាំងអស់។ បាទ អត់ដែលឮទេ។ បាទ អរគុណ។

**សៈ** លោកស្តាប់ឮគេផ្សាយ លោកអាចស្តាប់ការផ្សាយវិទ្យុសំឡេងកម្ពុជាប្រជាធិបតេយ្យទេ?

**ឆៈ** បាទ ក្នុងនោះ បាទឮ ប៉ុន្តែក៏មិនបានយកចិត្តទុកដាក់នឹងស្តាប់ដែរ ព្រោះពេលនោះការងារ

យោធា គឺថាមិនបានពេលស្តាប់ទេ។ បាទ យោធា គ្មានពេលស្តាប់ទេ អត់។ បើអ្នកណាក្បត់ គេលើកថាក្បត់តែម្តង បាទ ពេលនោះ។ អ្នកណាក្បត់អី ទោសអីៗ សេ.អ៊ី.អា ឬមួយទទួលស័ក្តិ២ ស័ក្តិ៣អី អាហ្នឹងគេប្រកាសប្រាប់តែម្តង។បើថាឲ្យស្តាប់ទៅតាមវិទ្យុជាចម្លើយសារភាពរបស់យួនរបស់អី ឃើញថា យោធាអត់សូវដែលបានស្តាប់ទេ។ បាទ ការងារយោធាជំនាន់នោះ ហ្វឹកហ្វឺនខ្លាំងមែនទែនតែម្តង។ ហ្វឹកហ្វឺនយ៉ាងម៉េច? ហ្វឹកហ្វឺនផ្នែក -- យប់ឡើងម៉ោងប្រាំមួយហែលទឹក។ ពីម៉ោងប្រាំមួយព្រឹកហែលទឹកហើយ ម៉ោងប្រាំពីររែកដី។ ក្រោយពីរែកដី ហូបបាយហើយសម្រាកបានតែមួយម៉ោងហ្នឹង ឆ្លៀតឱកាស បាទឆ្លៀតឱកាសការងារដែលជុំវិញទឹកន្លែងយោធាទេ។ ហើយដល់ម៉ោងធ្វើការទៀតហើយ អត់មានបានសម្រាក ឬមួយតម្រង់ខ្នងអីទេ គឺថាអត់ទេពេលវេលានោះ។ ដល់អ៊ីចឹងហើយកាលណាយោធាទាំងអស់នុ៎ង ខ្លួនខ្ញុំក៏អត់ដែលបានស្តាប់ បានដឹង បានឮនូវព័ត៌មានអ្វីមួយតាមវិទ្យុដែរ អត់សូវដែលបានស្តាប់ទេ។ បាទ អរគុណ។

[១៤:៣១:៥៩]

**ស៖** ក្នុងពេលរៀនសូត្រ ពេលដែលលោកបានចូលរួម ឬក៏ពេលដែលលោកនៅវរសេនាធំ តើលោកធ្លាប់បានពិភាក្សាគ្នាអំពីទស្សនាវដ្តីមួយដែលបានបោះពុម្ពផ្សាយដោយកម្ពុជាប្រជាធិបតេយ្យទេ? ឧទាហរណ៍ដូចជាឈ្មោះថា ទង់បដិវត្ត ឬក៏យុវជន-យុវនារីបដិវត្ត លោកធ្លាប់ឮទេ?

**ឆ៖** បាទ ក្នុងពេលនោះ ឮដែរ ប៉ុន្តែក៏មិនសូវចាប់អារម្មណ៍អីដែរ ទង់បដិវត្តកម្ពុជាប្រជាធិប-តេយ្យ។ បានតែឮ ប៉ុន្តែគ្រាន់តែឮ ហើយក៏អត់បានវិភាគអីទេ។ ដោយការយកចិត្តទុកដាក់ ការងារស្នូលបាទជាការងារស្នូលរបស់យោធា គឺថាដឹងតែការពារ ហើយនិងកសាងតែប៉ុណ្ណឹង។ អ៊ីចឹងការងារដែលផ្ទៃក្នុងគេផ្សេងៗ គឺថាអត់បានដឹង តែដឹងឮៗគ្រាន់តែឮថា “ទង់បដិវត្តកម្ពុជា” បាទឮ ដឹងតែប៉ុណ្ណឹទេ។ អរគុណ។

**ស៖** តើថ្នាក់លើមានបានប្រាប់ឲ្យថ្នាក់ក្រោមសិក្សាអំពីអត្ថបទដែលមានសរសេរនៅក្នុងទស្សនា-វដ្តីទង់បដិវត្ត ឬទស្សនាវដ្តីយុវជន-យុវនារីបដិវត្តទេ?

**ឆ៖** បាទ កាលនោះខ្ញុំអត់បានដឹងដែរ ហើយក៏ដឹងដែរ ហើយក៏ភ្លេចក៏មិនដឹង ព្រោះពេលនុ៎ងបានភ្លេចបាត់អស់ទៅហើយកាលនោះ។ បាទ សូមអរគុណ។

**ស៖** មុននេះលោកបានឆ្លើយថា នៅពេលចាប់ផ្តើមវគ្គរៀនសូត្រមានគ្រូចិនមកបង្រៀននាវិក។ ក្រៅពីគ្រូចិនទាំងអស់នេះ នៅក្នុងកងទ័ពជើងទឹកមានទីប្រឹក្សាចិន ដែលមានវត្តមានទេ?

**ឆ៖** បាទ អត់ដែលឃើញមានផង ទីប្រឹក្សារបស់ចិននៅនុំង។ បានឃើញទៅបើកវគ្គហ្នឹងមួយរយៈហ្នឹងហើយក៏គាត់ទៅបាត់អស់ទៅ អត់ដែលឃើញទេ មានតែគ្រូខ្មែរទេដែលនៅហ្វឹកហ្វឺនបង្រៀននោះ។ បាទ ខ្ញុំអត់បានដឹងទៀតដែរ។

[១៤:៣៤:០៣]

**ស៖** ចុះសម្ភារៈដែលលោកមាននៅក្នុងកងពល១៦៤ លោកដឹងថាសម្ភារៈទាំងនោះបានមកពីណាទេ? ខ្ញុំចង់សំដៅទៅលើអាវុធ គ្រាប់រំសេវ សម្ភារៈបច្ចេកទេស ឧទាហរណ៍ដូចជាវិទ្យុអីជាដើមនេះ ហើយចុះផ្កាយរណប ឬក៏រ៉ាដា លោកដឹងទេថាសម្ភារៈទាំងអស់ហ្នឹងបានមកពីណាដែរ?

**ឆ៖** បាទ រឿងនេះជារឿងពិតណាស់ សម្ភារៈយោធា ទាំងកាំភ្លើងតូច កាំភ្លើងធំ ទាំងនាវាតូច នាវាធំ និងសម្ភារៈប្រើប្រាស់ផ្នែកយោធា គឺថារបស់ចិនទាំងអស់ ទាំងវិទ្យុទាក់ទង រ៉ាដាសញ្ញាទូរលេខ ឃើញថា សុទ្ធតែរបស់ចិនទាំងអស់ទេ។ បាទ អរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយ លោកប្រធាន។ សូមអរគុណ។

[១៤:៣៦:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការនៅថ្ងៃនេះ ទោះបីនៅសេសសល់ពេលវេលាក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចធ្វើសវនាការបន្តបានដែរ ដោយហេតុសាក្សីរូបនេះ ជាសាក្សីថ្មីដែលអង្គជំនុំជម្រះទើបតែសម្រេចទទួលយក និងកោះហៅមកផ្តល់សក្ខីកម្មតាមសំណើរបស់សហព្រះរាជអាជ្ញា ហើយភាគីមេធាវីការពារក្តីបានស្នើសុំ ថាខ្លួនសុំមានពេលវេលា--

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអភ័យទោសលោកប្រធាន ដែលសុំកាត់។ ខ្ញុំធ្វើសេចក្តីជម្រាបខ្លីមួយមុននឹងសម្រាក លោកប្រធាន។ ខ្ញុំបានកត់សម្គាល់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតថា ចៅក្រមបានស្នើសុំឲ្យមានការដាក់ឯកសារទាក់ទងទៅនឹងដាក់ភស្តុតាងបន្ថែម ជាពិសេសទាក់ទងទៅនឹងអង្គជំនុំជម្រះតុលាការកំពូល ហើយនិងក្នុងការកោះហៅ រ៉ូបឺត ឡេមគីន ជាសាក្សី។ ហើយមានការជំនាស់ពីនៅតុលាការកំពូល ប៉ុន្តែយើងមិនបានជំទាស់ការកោះអញ្ជើញ ឡេមគីន នៅក្នុងការជំនុំជម្រះនៅក្នុងរឿងក្តី០០១ ហើយនៅក្នុង

រឿងក្តី០០២/០២ តុលាការបានជ្រាបហើយ យើងបានពិនិត្យមើលសក្ខីកម្មរបស់ ថេត សម្បត្តិ ហើយអ្វីដែល ឡោមគីន គាត់ដឹងពី ថេត សម្បត្តិ។ អ៊ីចឹង បើសិនជាលោក សម្បត្តិ មិនចង់ធ្វើសក្ខីកម្មទេ ហើយគប្បីតែពិចារណា ថាតើ ឡោមគីន អាចនឹងមានព័ត៌មានជម្រាបតុលាការដែរឬអត់ បើ ថេត សម្បត្តិ គាត់មិនធ្វើសក្ខីកម្មផង។ ហើយសហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការធ្វើសក្ខីកម្មរបស់ ឡោមគីន នៅក្នុងសវនាការរឿង០០២/០២នេះទេ។

[១៤:៣៨:៤១]

**ប្រធានអង្គជំនុំ៖**

មានភាគីណាមានមតិយោបល់អីលើបញ្ហានេះទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

កាលពីសប្តាហ៍មុន -- គឺបញ្ហាផ្សេងទេ។ កាលពីសប្តាហ៍មុន គឺមានការបញ្ជាក់ថាប្រហែលមានសំណើឲ្យស្តាប់សាក្សីផ្សេងទៀត ពាក់ព័ន្ធទៅនឹងប្រធានបទនៃការប្រព្រឹត្តចំពោះជនជាតិវៀតណាម។ ដូច្នេះ លោកសហព្រះរាជអាជ្ញាអាចបញ្ជាក់បានទេ ថាយើងនឹងទទួលបានសំណើនេះនៅពេលណា? លោកគិតថា ប្រហែលជានឹងដាក់សំណើនេះនៅពេលណាដែរ?

**លោក នីកូឡាស គូមជែន៖**

បើតុលាការអនុញ្ញាត សូមអនុញ្ញាតនោះ ខ្ញុំនឹងឆ្លើយតបទៅនឹងអ៊ីម៉ែលទៅអង្គជំនុំជម្រះ ហើយនិងចម្លងជូនភាគីទាំងអស់នៅថ្ងៃនេះ ដើម្បីជម្រាបជូនថាតើយើងនឹងដាក់ឯកសារដែរឬអត់? ព្រោះខ្ញុំមិនទាន់បានត្រៀមខ្លួននឹងឆ្លើយតបនៅពេលនេះទេ ប៉ុន្តែខ្ញុំនឹងឆ្លើយតបមុនបញ្ចប់ការងារថ្ងៃនេះ តាមអ៊ីម៉ែលបាទ។

[១៤:៣៩:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកធ្វើដូច្នេះទៅចុះ។

បាទ សាជាថ្មីម្តងទៀត ហើយសវនាការថ្ងៃនេះទោះបីនៅសល់ពេលវេលាក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចធ្វើសវនាការបន្តទៅទៀតបានដែរ ដោយហេតុថាសាក្សីរូបនេះជាសាក្សីថ្មី ដែលអង្គជំនុំជម្រះទើបតែសម្រេចទទួលយក និងកោះហៅមកផ្តល់សក្ខីកម្មតាមសំណើសុំរបស់សហព្រះរាជអាជ្ញា

ហើយភាគីសហមេធាវីការពារក្ដីទាំងពីរក្រុមបានស្នើសុំថាខ្លួនសុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំពិនិត្យឯកសារភស្តុតាងដែលពាក់ព័ន្ធនឹងសាក្សីនេះជាមុនសិន មុននឹងខ្លួនប្រើប្រាស់ពេលវេលាក្នុងការតាំងសួរដេញដោលចំពោះសាក្សីរូបនេះ។

ហើយដោយនៅថ្ងៃស្អែកនេះ ក៏ជាថ្ងៃចុងក្រោយនៃកាលវិភាគសវនាការដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការពិនិត្យភស្តុតាងលើសំណុំរឿង០០២/០២ នៅក្នុងឆ្នាំ២០១៥នេះដែរ។ ហេតុដូច្នេះ ដល់ពេលនេះត្រូវឈប់សម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1000 បញ្ចប់ និងអាចផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-848។ ឯបញ្ជីឈ្មោះសាក្សីដើមបណ្ដឹងរដ្ឋប្បវេណីអ្នកជំនាញ ដែលនឹងត្រូវកោះហៅមកផ្ដល់សក្ខីកម្មជាបន្តបន្ទាប់សម្រាប់ខែមករា ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងជម្រាបជូនភាគីក្នុងរយៈពេលសមស្រប តាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

ហើយអង្គជំនុំជម្រះអរគុណលោកសាក្សី 2-TCW-1000 ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០១៦ ជាបន្តទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកសាក្សីរូបនេះត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅ ហើយនិងឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញនៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

[១៤:៤២:១៦]

ហើយអង្គជំនុំជម្រះអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី។ លោកអាចសម្រាកបានហើយ ហើយអង្គជំនុំជម្រះក៏អញ្ជើញលោកមកប្រឹក្សាសាក្សីរូបនេះនៅ -- ដែលនឹងបន្តធ្វើសវនាការនៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក

ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃអង្គារ ទី០៥ ខែមករា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៤៣ នាទី)*